# ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

# សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា
# ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

# នីតិវិធីសវនកម្មរបស់ក្រុមហ៊ុនខេ ភី អឹម ជី ខេមបូឌា លើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អ៊ូរី (ខេមបូឌា)ម.ក

AUDIT PROCEDURE OF K P M G CAMBODIA LTD ON FINANCIAL STATEMENT OF WOORI BANK (CAMBODIA) PLC.

**ជំនាញៈ សវនកម្ម**

**រៀបរៀងដោយៈ គន គីមហុង**

**អត្តលេខៈ** MA21/010

**ឆ្នាំសិក្សា ៖ ឆ្នាំ២០២៣ - ២០២៥**

# ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

# សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា
# ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

## នីតិវិធីសវនកម្មរបស់ក្រុមហ៊ុនខេ ភី អឹម ជី ខេមបូឌា លើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អ៊ូរី (ខេមបូឌា)ម.ក

AUDIT PROCEDURE OF K P M G CAMBODIA LTD ON FINANCIAL STATEMENT OF WOORI BANK (CAMBODIA) PLC.

ជំនាញ: សវនកម្ម

សាស្ត្រាចារ្យណែនាំ ៖ បណ្ឌិត កង ឱម

លោកគ្រូណែនាំ ៖ បេក្ខបណ្ឌិត យ៉ែម សុខហៀក

ឆ្នាំសិក្សា ៖ ឆ្នាំ២០២៣ - ២០២៥

**គណៈកម្មការត្រួតពិនិត្យរបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា**
**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី២១**
**ប្រធានបទៈ សវនកម្មរបស់ក្រុមហ៊ុនសវនករឯករាជ្យ លើរបាយការណ៍ហិរញ្ញវត្ថុ**
**របស់ធនាគារ អ៊ូរី (ខេមបូឌា)ម.ក**

| | |
|---|---|
| លោកគ្រូណែនាំ | សាស្ត្រាចារ្យណែនាំ |
| បេក្ខបណ្ឌិត យ៉ែម សុខហៀក | បណ្ឌិត កង ឱម |
| សាកលវិទ្យាធិការរងអចិន្ត្រៃយ៍ | ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ |
| បណ្ឌិត ហ៊ូ គុជគន្ធលីនណា | បណ្ឌិត សេង សំអឿន |

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

# ឧទ្ទិសស្នាដៃ

ខ្ញុំបាទ **គន គីមហុង** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី២១ ជំនាញ**សវនកម្ម** នៃសាកលវិទ្យាល័យវ៉ាន់ដា។

សូមឧទ្ទិសស្នាដៃ នៃកិច្ចការស្រាវជ្រាវនេះថ្វាយចំពោះវិញ្ញាណក្ខន្ធ វីរព្រះមហាក្សត្រខ្មែរ គ្រប់សម័យកាលដែលព្រះអង្គបានធ្វើព្រះរាជនីយកិច្ច ដើម្បីបុព្វហេតុជាតិ និងមាតុភូមិ។

សូមឧទ្ទិសស្នាដៃ នៃការកិច្ចការស្រាវជ្រាវនេះ ថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធមេដឹកនាំខ្មែរ គ្រប់សម័យកាលដែលបានធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីបុព្វហេតុជាតិ ប្រជាជន និងទឹកដីខ្មែរ។

សូមឧទ្ទិសស្នាដៃ នៃកិច្ចការស្រាវជ្រាវនេះ ជូនចំពោះវិញ្ញាណក្ខន្ធយុទ្ធជន យុទ្ធនារី កុលបិត្រ កុលធីតា និងជនរួមជាតិខ្មែរគ្រប់រូប ពុទ្ធបរិស័ទ្ធខ្មែរ និងជនស្នេហាជាតិទាំងអស់ ដែលបានធ្វើពលិកម្មនៅគ្រប់សម័យកាលដើម្បីបុព្វហេតុជាតិ មាតុភូមិ និងប្រជានពលរដ្ឋរបស់យើងទាំងអស់គ្នា។

សូមឧទ្ទិសស្នាដៃ នៃកិច្ចការស្រាវជ្រាវនេះ ជូនចំពោះពុទ្ធបរិស័ទខ្មែរ និងជនស្នេហាជាតិទាំងអស់ដែលបានលះបង់ធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីបុព្វហេតុជាតិមាតុភូមិ។

សូមឱ្យមាតុភូមិជាតិនៃកម្ពុជា ស្ថិតនៅគង់វង្ស មានភាពរុងរឿងសម្បូរសប្បាយ មានភាពថ្លៃថ្នូរ និងថ្កុំថ្កើនតរៀងទៅ។

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញសវនកម្មនៅសាកលវិទ្យាល័យនវ៉ាន់ដា អស់រយៈពេល២ឆ្នាំរួចមកខ្ញុំបាទបានទទួលនូវចំណេះដឹងជាច្រើន ដែលបានពាក់ព័ន្ធនឹងមុខវិជ្ជាសវនកម្ម គណនេយ្យពន្ធ ជាពិសេសយល់ច្បាស់ថាជំនាញសវនកម្ម គឺជាជំនាញមួយដ៏មានសារៈសំខាន់សម្រាប់គម្រូវការស្ថាប័នទាំងអស់ មិនថាស្ថាប័នរដ្ឋ ស្ថាប័នឯកជន ឬអង្គការក្រៅរដ្ឋាភិបាលឡើយ។ ក្នុងនោះផងដែរដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែស៊ីជម្រៅលើជំនាញរបស់ខ្លួន សាកលវិទ្យាល័យក៏បានបញ្ចូលមុខវិជ្ជាជាច្រើន ដែលពាក់ព័ន្ធទៅនឹងកម្មវិធីសិក្សាទៅតាមកម្រិត ពីឆ្នាំទីមួយ រហូតដល់ឆ្នាំទីពីរដែលត្រូវបញ្ចប់ការសិក្សា។

គ្រប់មុខវិជ្ជាទាំងអស់សុទ្ធតែជាយានសម្រាប់ឱ្យនិស្សិតយកទៅប្រើប្រាស់នៅក្នុងវិស័យការងារបានជាពិសេសនោះ គឺមុខវិជ្ជាគណនេយ្យដែលស្ថាប័នត្រូវឱ្យបុគ្គលិកពាក់ព័ន្ធត្រូវមានចំណេះដឹងដើម្បីរៀបចំបញ្ជីកា និងកាន់កាប់បញ្ជីគណនេយ្យ ឱ្យបានត្រឹមត្រូវស្របទៅតាមការណែនាំរបស់អគ្គនាយកដ្ឋានពន្ធដារ និងដើម្បីជៀសវាងនូវបញ្ហាផ្សេងៗដែលអាចកើតមានឡើង ឬធ្វើឱ្យមានការរាំងស្ទះដល់ដំណើរការនៃអាជីវកម្មទៅថ្ងៃក្រោយ ដោយឱ្យខ្ញុំបាទយល់ថាចំណេះដឹងខាងគណនេយ្យជាចំណេះដឹងបន្ថែមមួយទៀតដ៏មានសារៈសំខាន់សម្រាប់សវនករទាំងអស់ធ្វើការសិក្សាស្វែងយល់ និងស្របពេលដែលខ្ញុំបាទមានឱកាសក្នុងការបានសរសេររបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផងនោះទើបខ្ញុំបាទសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយ ស្តីអំពី « **សវនកម្មរបស់ក្រុមហ៊ុនសវនករឯករាជ្យលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក** » យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជារបាយការណ៍ក្នុងគោលបំណងឱ្យអ្នកអាន និងអ្នកស្រាវជ្រាវក្រោយៗទៀតឱ្យយល់កាន់តែច្បាស់ពីគណនេយ្យ។ ខ្ញុំក៏សង្ឃឹមថាការរៀបចំរបាយការណ៍ស្រាវជ្រាវនេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកដទៃទៀតដែលមានបំណងលើការសិក្សាពីជំនាញគណនេយ្យ។

ជាទីបញ្ចប់ខ្ញុំបាទ សូមមេត្តាខន្តីអភ័យទោសពីសំណាក់សាស្ត្រាចារ្យ រាមច្បង និងមិត្តអ្នកអាន នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនានៅក្នុងរបាយការណ៍ស្រាវជ្រាវនេះ ហើយខ្ញុំបាទក៏រីករាយនិងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយៗទៀតមានភាពល្អប្រសើរ។

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី២១ ជំនាញសវនកម្មនៃសាកលវិទ្យាល័យវ៉ាន់ដា។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ**

លោកឪពុក និងអ្នកម្តាយដែលបានផ្តល់កំណើត ហើយខិតខំបីបាច់ថែរក្សាកូន ព្រមទាំងផ្គត់ផ្គង់ដល់កូនសព្វបែបយ៉ាង ខិតខំលើកទឹកចិត្តកូនក្នុងការសិក្សា តាំងពីកូនចូលរៀនដំបូងរហូតមកដល់ពេលនេះ និងបានបង្រៀនកូនឱ្យចេះស្នេហាជាតិមាតុភូមិកម្ពុជា។

នាយក គណៈគ្រប់គ្រង បុគ្គលិក សាស្ត្រាចារ្យនៃសាកលវិទ្យាល័យវ៉ាន់ដា ដែលជានិច្ចកាលតែងតែផ្តល់នូវការលើកទឹកចិត្ត អនុគ្រោះដល់ខ្ញុំបាទរហូតធ្វើឱ្យការសិក្សាបានបញ្ចប់និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ជាពិសេសសាស្ត្រាចារ្យ **បណ្ឌិត ភង ឱម** និងលោកគ្រូ **យ៉េម សុខហៀក** ដែលលោកបានឆ្លៀតពេលវេលាដ៏មានតម្លៃដើម្បីជួយណែនាំដល់ការសរសេររបាយការណ៍ របស់ខ្ញុំបាទឱ្យរឹតតែមានភាពល្អប្រសើរ។

ជាទីបញ្ចប់ខ្ញុំបាទសូមលើកដៃសំពះបួងសួងដល់គុណព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោកជួយបីបាច់ថែរក្សាដល់លោកអ្នកមានគុណខាងលើឱ្យជួបតែសេចក្តីសុខគ្រប់ប្រការកុំបីអាក់ខានឡើយ។

សូមគោរពជូនពរដល់គុណូបការជនទាំងអស់ សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ ដ៏មហាប្រសើរ គឺះ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ខ្ញុំបាទសូមធានាអះអាង និងទទួលខុសត្រូវលើខ្លឹមសារនៅក្នុងរបាយការណ៍ស្រាវជ្រាវនេះថា ពិតជារបាយការណ៍ស្រាវជ្រាវ និងជាស្នាដៃស្រាវជ្រាវផ្ទាល់របស់ខ្ញុំបាទដោយគ្មានពាក់ព័ន្ធជាមួយនឹងសារណា ឬជារបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ចំពោះទិន្នន័យលទ្ធផលនៃការស្រាវជ្រាវដែលប្រមូលបានក្នុងរបាយការណ៍ស្រាវជ្រាវនេះ គឺថ្មីហើយក៏មិនទាន់មានជនណាម្នាក់យកទៅប្រើប្រាស់នៅក្នុងសារណា ឬយកមកធ្វើជារបាយការណ៍ស្រាវជ្រាវរបស់គេឡើយ។

ភ្នំពេញ ថ្ងៃទី..........ខែ............ឆ្នាំ.........

**ហត្ថលេខា**

ថ្ងៃ..................ខែ................ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

ភ្នំពេញ ថ្ងៃទី..........ខែ............ឆ្នាំ២០២៥

**គ្រូណែនាំ**

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

របាយការណ៍សិក្សាស្រាវជ្រាវទៅលើប្រធានបទ « **សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក** » ដោយបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រព័ន្ធគ្រប់គ្រងសវនកម្មហិរញ្ញវត្ថុដែលក្នុងនោះយើងលើកយកចំនុនសំខាន់ៗមកធ្វើការអង្កេត ពិនិត្យនិងអនុវត្តចំនួន៥ ដែលជាគោលដៅចំបងក្នុងកិច្ចការស្រាវជ្រាវរបស់យើងគឺៈ

១). ការធ្វើសវនកម្មទៅលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ

២). ការធ្វើសវនកម្មទៅលើរបាយការណ៍ចំណេញ ឬខាត

៣). ការធ្វើសវនកម្មទៅលើរបាយការណ៍លំហូរទឹកប្រាក់

៤). ការធ្វើសវនកម្មទៅលើរបាយការណ៍កំណត់សម្គាស់ និង

៥). ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ធនាគារ

ជាគោលបំណងក្នុងការស្វែងយល់អំពីប្រព័ន្ធនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ និងជាការអនុវត្តន៍ទៅលើកិច្ចការស្រាវជ្រាវផ្នែកសវនកម្មហិរញ្ញវត្ថុមួយដែលយើងរៀបរៀងឡើង នឹងជាបទពិសោធន៍ផ្នែករបាយការណ៍បញ្ចាប់ការសិក្សាថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសវនកម្មផងដែរ។

ក្រោយពីបានធ្វើការសិក្សាទៅលើចំណុចខាងលើឃើញថាធនាគារ អ៊ូរី (ខេមបូឌា) ម.ក ការអនុវត្តរបស់ក្រុមប្រឹក្សាភិបាលគឺលទ្ធផលនៃការប្រតិបត្តិការ ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនរងផលប៉ះពាល់ជាសារវន្តពីសកម្មភាពប្រតិបត្តិការ ព្រឹត្តិការណ៍ ឬជាគុណាមួយមិនបានប្រក្រតីនោះទេ ដែលអាចនាំឱ្យប៉ះពាល់លទ្ធផលនៃប្រតិបត្តិការរបស់ធនាគារ ក្នុងការិយបរិច្ឆេទដែលរបាយការណ៍ហិរញ្ញវត្ថុនេះបានរៀបឡើងនោះទេ

ដូច្នេះយើងសូមធ្វើការអនុម័តទៅលើរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយថា បានបង្ហាញនូវភាពត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទិននឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ស.រ.ទ.ហ.អ.ក)។

# Research Summary

A research report on the topic of "Audit on the Financial Statements of **Woori Bank (Cambodia) Co., Ltd.**" by conducting a study on the financial audit management system in which we highlight the main points to observe, review and implement 5. The main objectives of our research are:

1). Auditing the bank's financial statement
2). Auditing the profit or loss statement
3). Auditing the cash flow statement
4). Auditing the balance sheet and
5). Financial risk management of the bank

The purpose is to understand the bank's financial management system and to implement a financial audit research that we have prepared, which will also be an experience in the final report of the Master's degree in auditing.

Having studied the above points, it is found that the performance of the Board of Directors of **Woori Bank (Cambodia) Co., Ltd.** is not materially affected by any unusual transaction, event or item that may have affected the results of the Bank's operations for the period under review.

We therefore approve the accompanying financial statements as presenting fairly, in all material respects, the financial position of the Bank as at 31 December 2023, and its financial performance and cash flows for the period then ended in accordance with Cambodian International Financial Reporting Standards (CIFRS).

# មាតិកា

ទំព័រ


ឧទ្ទិសស្នាដៃ ........................................ i
អារម្ភកថា ........................................ ii
សេចក្តីថ្លែងអំណរគុណ ........................................ iii
អំណះអំណាង ........................................ iv
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........................................ v
Research Summary ........................................ vi


## ជំពូកទី១: សេចក្តីផ្តើម


១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........................................ ១-២
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........................................ ២
១.៣ គោលបំណងនៃការស្រាវជ្រាវ ........................................ ២-៣
១.៤ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........................................ ៣
 ១.៤.១ វិសាលភាពនៃការស្រាវជ្រាវ ........................................ ៣
 ១.៤.២ ដែនកំណត់នៃការសិក្សាស្រាវជ្រាវ ........................................ ៣
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ........................................ ៤
 ១.៥.១ វិធីសាស្ត្រស្រាវជ្រាវ ........................................ ៤
 ១.៥.២ វិធីសាស្ត្រប្រមូលទិន្នន័យ ........................................ ៤
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........................................ ៤-៥
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................ ៥


## ជំពូកទី២: ទ្រឹស្តីពាក់ព័ន្ធ


២.១ ស្ថានភាពទូទៅលើរបាយការណ៍សវនកម្មហិរញ្ញវត្ថុរបស់ធនាគារ ........................................ ៦
 ២.១.១ និយមន័យធនាគារ ........................................ ៦
 ២.១.២ ប្រវត្តិរបស់ធនាគារ ........................................ ៦-៧
 ២.១.៣ ប្រភេទធនាគារ ........................................ ៧
២.២ វិធីសាស្ត្រ និងនីតិវិធីសម្រាប់សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ........................................ ៨
 ២.២.១ និយមន័យរបាយការណ៍ហិរញ្ញវត្ថុ ........................................ ៨
 ២.២.២ ប្រវត្តិរបាយការណ៍ហិរញ្ញវត្ថុ ........................................ ៨-៩
 ២.២.៣ សមាសធាតុរបាយការណ៍ហិរញ្ញវត្ថុ ........................................ ៩
២.៣ ផលប្រយោជន៍នៃការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ........................................ ១០
 ២.៣.១ និយមន័យសវនកម្ម ........................................ ១០
 ២.៣.២ ប្រវត្តិនៃសវនកម្ម ........................................ ១០-១១

២.៣.៣ ប្រភេទសវនកម្ម ........................................................................................................ ១១-១៣

## ជំពូកទី៣: នីតិវិធីនៃការធ្វើសវនកម្មរបស់ក្រុមហ៊ុនខេ ភី អឹម ជី ខេមបូឌា លើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

៣.១ ស្ថានភាពទូទៅរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក............................................................. ១៤
៣.១.១ ប្រវត្តិរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ................................................................... ១៤
៣.១.២ ទស្សនវិស័យ ឬបេសកកម្មរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ....................................... ១៥
៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក .......................................១៥-១៨
៣.២ វិធីសាស្ត្រ និងនីតិវិធីរបស់សវនករផ្ទៃក្រៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អ៊ូរី ...........១៨-១៩
៣.២.១ វិធីសាស្ត្រនៃការធ្វើសវនកម្មរបស់ក្រុមហ៊ុនខេ ភី អឹម ជី ខេមបូឌា ......................... ១៩-២០
៣.២.២ នីតិវិធីនៃការធ្វើសវនកម្មរបស់ក្រុមហ៊ុនខេ ភី អឹម ជី ខេមបូឌា ...............................២០-២១
៣.៣. ផលប្រយោជន៍សវនកម្មរបាយការណ៍ហិរញ្ញវត្ថុធនាគារ អ៊ូរី (ខេមបូឌា) ម.ក...................២១-២២
៣.៣.១ ផលប្រយោជន៍នៃការធ្វើសវនកម្មរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក..................២២-២៨
៣.៣.២ ផលប្រយោជន៍សម្រាប់អ្នកប្រើប្រាស់របាយការណ៍សវនកម្មហិរញ្ញវត្ថុ...................២៨-២៩

## ជំពូកទី៤: ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំងរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក .............................................៣០-៣២
៤.២ ការវិភាគលើចំណុចខ្សោយ ឬខ្វះចន្លោះនៃការគ្រប់គ្រង ........................................................៣២

## ជំពូកទី៥: សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ..................................................................................................... ៣៣
៥.២ ការផ្តល់អនុសាសន៍ ........................................................................................... ៣៣-៣៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុគឺជាដំណើរការសំខាន់សម្រាប់ធនាគារដើម្បីវាយតម្លៃសមត្ថភាព និងគុណភាពនៃសេវាកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុនិងឥណទានរបស់ខ្លួនទៅតាមផែនការណ៍បានកំណត់។ ដោយនៅប្រទេសកម្ពុជាយើងដែលមានការអភិវឌ្ឍន៍យ៉ាងលឿនក្នុងវិស័យហិរញ្ញវត្ថុ និងធនាគារ។ ហើយការធ្វើសវនកម្មនេះកាន់តែមានសារៈសំខាន់ក្នុងការទប់ស្កាត់បញ្ហាដែលអាចកើតមានឡើងនិងជាការជួយកែលម្អសេវាកម្មឱ្យកាន់តែប្រសើរជាងមុនថែមទៀតផង។ ដូចជាការវាយតម្លៃគុណភាពដើម្បីធានាថា សេវាកម្មមានគុណភាព និងអាចបំពេញតម្រូវការរបស់អតិថិជនយល់ដឹងពីតម្រូវការ និងចំណង់ចំណូលចិត្តរបស់អតិថិជន ការចាប់អារម្មណ៍លើការប្រាស្រ័យទាក់ទងជាមួយអតិថិជន និងបុគ្គលិករួមទាំងការប្រើប្រាស់ទិន្នន័យដើម្បីជាការវាយតម្លៃស្ថានភាពនិងគុណភាពសេវាកម្ម។ដោយងាកមកមើលច្បាប់និងបទប្បញ្ញត្តិស្តីពីកាតព្វកិច្ចនៃការដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់និយ័តករគណនេយ្យ និងសវនកម្មដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា តម្រូវឱ្យគ្រប់ស្ថាប័នគ្រឹះស្ថាន សហគ្រាស ក្រុមហ៊ុនរដ្ឋ និងក្រុមហ៊ុនឯកជននានាត្រូវកាន់បញ្ជីការគណនេយ្យហិរញ្ញវត្ថុឱ្យស្របទៅតាមស្តង់ដារគណនេយ្យជាតិនៃកម្ពុជា **CIFRS & CIAS** រួមទាំងស្តង់ដាសវនកម្មរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុរបស់ប្រព័ន្ធធនាគារ អ៊ូរី (ខេមបូឌា) ម.ក គឺដើម្បីការពារសុវត្ថិភាពទិន្នន័យរបស់ធនាគារសម្រាប់ធ្វើការអនុវត្តន៍ និងការពិនិត្យស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារឱ្យមានភាពត្រឹមត្រូវដោយផ្អែកលើស្តង់ដារហិរញ្ញវត្ថុដែលទទួលស្គាល់ដោយស្ថាប័នជាតិនៃកម្ពុជា។ ការគ្រប់គ្រង និងការផ្តល់នូវរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របាយការណ៍ប្រាក់ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗនៃរបាយការណ៍ស្តីពីបម្រែបម្រួលមូលធន របាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ រួមទាំងរបាយការណ៍កំណត់សម្គាល់ ដែលរួមមានគោលនយោបាយណ៍គណនេយ្យសារវន្ត ព្រមទាំងព័ត៌មានពន្យល់ផ្សេងទៀតនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបានភ្ជាប់មកជាមួយបានបង្ហាញនូវភាពត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ព្រមទាំងលទ្ធផលហិរញ្ញវត្ថុនិងជាលំហូរសាច់ប្រាក់របស់ធនាគារសម្រាប់ការិយបរិច្ឆេទ ដែលត្រូវបានបញ្ចប់ដោយអនុលោមទៅតាមស្តង់ដារនៃរបាយការណ៍ទាក់ទងជាមួយ នឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ស.រ.ទ.ហ.អ.ក)។

ជាក់ស្តែងធនាគារ អ៊ូរី (ខេមបូឌា) ម.ក ធ្វើការគ្រប់គ្រងហានិភ័យប្រតិបត្តិការនៃការបាត់បង់ផ្ទាល់ ឬប្រយោលដែលកើតមានឡើងពីការខ្វះខាតឬជាការអនុវត្តមិនមានប្រសិទ្ធភាពនូវនីតិវិធីដំណើរការផ្ទៃក្នុងរបស់បុគ្គលិក ឬប្រព័ន្ធ ឬពីកត្តាខាងក្រៅផ្សេងទៀត។ ហានិភ័យនេះគឺ ត្រូវបានគ្រប់គ្រងតាមរយៈការបង្កើតប្រព័ន្ធដំណើរការគ្រប់គ្រងប្រតិបត្តិការ ការត្រួតពិនិត្យ និងការរាយការណ៍ឱ្យបានត្រឹមត្រូវពីសកម្មភាពអាជីវកម្មតាមរយៈការគ្រប់គ្រងនិងត្រួតពិនិត្យពីគណៈគ្រប់គ្រង់ជាន់ខ្ពស់។ ទាំងនេះគឺរួមមានហានិភ័យខាងផ្នែកច្បាប់តាមច្បាប់អនុលោម (ផ្តល់ផលអាក្រក់) តាមបែបគណនេយ្យ និងការក្លែងបន្លំគណនេយ្យ។

ការគ្រប់គ្រងហានិភ័យប្រតិបត្តិការរបស់ប្រព័ន្ធធនាគារ អ៊ូរី (ខេមបូឌា) ម.ក តម្រូវឱ្យបង្កើតនូវរចនាសម្ព័ន្ធ-

តួនាទីនិងវិធីសាស្ត្រនៃការគ្រប់គ្រងរបស់អង្គភាពឱ្យបានច្បាស់លាស់។ គោលការណ៍និងវិធានការត្រួតពិនិត្យផ្ទៃក្នុងជាច្រើនត្រូវបានអនុវត្ត រួមមានការបង្កើតអ្នកមានសិទ្ធិចុះហត្ថលេខា ប្រព័ន្ធត្រួតពិនិត្យយ៉ាងហ្មត់ចត់ ការរៀបចំនូវនីតិវិធី និងឯកសារយោងនានាព្រមទាំងការអនុវត្តតាមបទប្បញ្ញត្តិ និងតម្រូវការតាមច្បាប់នានា។ ដំណើរការទាំងនេះត្រូវបានត្រួតពិនិត្យជាប្រចាំឆ្នាំ ដើម្បីឆ្លើយតបទៅនឹងហានិភ័យប្រតិបត្តិការដែលអាចកើតឡើងនៅក្នុងប្រតិបត្តិការអាជីវកម្មរបស់ធនាគារ។

## ១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ជាទូទៅរាល់ប្រតិបត្តិនៃការស្រាវជ្រាវ ការគ្រប់គ្រង ឬការសិក្សាទៅលើប្រធានបទអ្វីមួយនោះទេគឺពួកយើងតែងតែជួបនៅបញ្ហាប្រឈមនានា ដូចជាគុណភាពទិន្នន័យប្រហែលជាមិនសមស្រប ឬមានកំហុសឆ្គងណាមួយដែលអាចបណ្តាលឱ្យមានការប្រៀបធៀបមិនត្រឹមត្រូវ បញ្ហាវិធីសាស្ត្រស្រាវជ្រាវ ដែលប្រើប្រាស់អាចមិនសមស្រប ឬអាចមិនបានជ្រើសរើសយ៉ាងច្បាស់ដែលអាចប៉ះពាល់ដល់លទ្ធផលការអភិវឌ្ឍន៍ឧស្សាហ៍កម្មអាចបង្កើតឱ្យមានការប្រែប្រួលក្នុងការវិភាគហើយអាចប៉ះពាល់ដល់សមត្ថភាពស្វែងយល់។ ការធ្វើការប្រកួតប្រជែង ស្ថានភាពប្រកួតប្រជែងគឺ អាចបង្កើតឱ្យមានការពិបាកក្នុងការវាយតម្លៃសមត្ថភាពរបស់ធនាគារមួយច្បាស់និងការត្រួតពិនិត្យសម្រាប់ធនាគារ គឺប៉ះពាល់ដល់ការប្រតិបត្តិនិងការស្រាវជ្រាវ ការគ្រប់គ្រងហិរញ្ញវត្ថុសមត្ថភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងការប្រើប្រាស់ធនធានអាចជាអត្តសញ្ញាណនៃការស្រាវជ្រាវអំពីសវនកម្មបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវការពិចារណាពីចំណោទបញ្ហាដើម្បីស្វែងរកដំណោះស្រាយដែលត្រឹមត្រូវ និងអាចអនុវត្តបាន។ ដូច្នេះហើយបានជាការស្រាវជ្រាវទៅលើប្រធានបទ សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ខាងលើយើងក៏មានចំណោទបញ្ហាពីរដែលត្រូវយកមកចោទសួរផងដែរគឺៈ

១)តើសវនករផ្ទៃក្រៅមានវិធីសាស្ត្រ និងនិតិវិធីអ្វីខ្លះសម្រាប់ធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ?

២)តើការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុផ្តល់ផលប្រយោជន៍អ្វីខ្លះ?

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវអំពីសវនកម្មរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក មានចំណុចសំខាន់ៗដូចជាៈការវាយតម្លៃសមត្ថភាពហិរញ្ញវត្ថុនៃធនាគារនៅក្នុងការប្រតិបត្តិនិងការអភិវឌ្ឍន៍អំពីការស្រាវជ្រាវអំពីគុណភាពសេវាកម្មការពិនិត្យនិងវាយតម្លៃគុណភាពសេវាកម្ម ដែលធនាគារផ្តល់ជូនដល់អតិថិជន កំណត់បញ្ហា និងឱកាសនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ និងស្វែងរកឱកាសសម្រាប់ការអភិវឌ្ឍន៍ការកែលម្អគោលការនិងគោលនយោបាយណ៍និងការអនុវត្តផ្តល់អនុសាសន៍សម្រាប់ការកែលម្អគោលនយោបាយណ៍និងការអនុវត្តដើម្បីសម្រួលសេវាកម្មនិងការបង្កើនភាពប្រសើរនៅក្នុងទីផ្សារជំរុញភាពប្រសើរឡើងនៃធ្វើការប្រកួតប្រជែងក្នុងទីផ្សារហើយបង្កើតប្រយោជន៍សម្រាប់អតិថិជន។ នៃការប្រើប្រាស់ធនធានស្វែងយល់ពីរបៀបដែលធនាគារប្រើប្រាស់ធនធាននិងការវាយតម្លៃសមត្ថភាពក្នុងការគ្រប់គ្រងនិងបង្កើនប្រសិទ្ធភាពក្នុងការស្តារប្រាក់និងការប្រព្រឹត្តអាជីវកម្មពិនិត្យស្ថានភាពស្តារប្រាក់និងការប្រព្រឹត្តអាជីវកម្មគឺៈ ដើម្បីជួយកែលម្អអំពីស្ថានភាពហិរញ្ញវត្ថុដែលសម្រាប់ជាគោលបំណងនៃការស្រាវជ្រាវនេះអាចធ្វើឱ្យមានការយល់ដឹងច្បាស់អំពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនិងអាចជួយធនាគារ នូវក្នុងការអភិវឌ្ឍន៍យ៉ាងមានប្រសិទ្ធភាព។

ដោយគោលបំណងនៃការសិក្សា និងត្រួតពិនិត្យមើលលើការអនុវត្តការគ្រប់គ្រងចលនាសាច់ប្រាក់ជារួមរបស់

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក មានដូចជា៖

- ការយល់ដឹងអំពីនិតិវិធី និងវិធីសាស្ត្រនៃការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ
- ស្វែងយល់ពីអត្ថប្រយោជន៍នៃការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ
- ទិដ្ឋភាពទូទៅរបស់ធនាគារ
- គោលការណ៍ និងគោលនយោបាយណ៍បទដ្ឋានសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ
- របៀបនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ប្រព័ន្ធធនាគារ
- ការវិភាគទៅលើចំណុចខ្លាំង និងចំណុចខ្សោយរបស់ធនាគារ
- បទពិសោធន៍ ចំណេះដឹងដែលទាក់ទងទៅនឹងគោលការណ៍របស់ធនាគារ និងការសន្និដ្ឋានរួមជាមួយ និងការផ្ដល់អនុសាសន៍ចំពោះចំណុចខ្វះខាតមួយចំនួនរបស់ធនាគារផងដែល។

## ១.៤ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ វិសាលភាពនៃការស្រាវជ្រាវ

ដែនកំណត់ និងវិសាលភាព នៃកិច្ចការស្រាវជ្រាវអំពីសវនកម្មលើរបាយកាណ៍រហិរញ្ញវត្ថុរបស់ប្រព័ន្ធធនាគារ អ៊ូរី (ខេមបូឌា) ម.ក ក៏មានចំណុចសំខាន់ៗដូចជា៖ ទីតាំងភូមិសាស្ត្រការស្រាវជ្រាវអាចកំណត់នៅក្នុងតំបន់ជាក់លាក់ឬខេត្តដែលធនាគារមានទីតាំងសាសាខា ឬសេវាកម្មគ្រប់ប្រភេទរបស់នាគារ និងលក្ខណៈរបស់ធនាគារ (ឧ. ធនាគារធំ ឬ ធនាគារតូច) អាចមានឥទ្ធិពលលើការស្រាវជ្រាវ រយៈពេលនៃការស្រាវជ្រាវអាចកំណត់ក្នុងរយៈពេលជាក់លាក់ដើម្បីវាយតម្លៃការកំណត់ឡើងវិញ និងការអភិវឌ្ឍន៍។

ការសិក្សាទៅលើប្រធានបទ (ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ) ខាងលើយើងលើកយកតែបញ្ហាមួយចំនួនដែលសិក្សាអំពីនីតិវិធីនិងគោលនយោបាយណ៍ទាំងមូលរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក នៃការិយាល័យចុះបញ្ជីរបស់ធនាគារ ដែលមានទីតាំងស្ថិតនៅ អគារលេខ 398 មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

### ១.៤.២. ដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ប្រភពទិន្នន័យ៖ ប្រើប្រាស់ទិន្នន័យពីប្រភពជាក់លាក់ ដូចជាផែនការហិរញ្ញវត្ថុ ឬ របាយការណ៍របស់សហគ្រាសវិសាលភាពការវិភាគសេដ្ឋកិច្ច ស្រាវជ្រាវអំពីផលប៉ះពាល់នៃសវនកម្មទៅលើសេដ្ឋកិច្ចក្នុងតំបន់ជាសេវាកម្មហិរញ្ញវត្ថុពិនិត្យគុណភាពនិងភាពស្របតាមតម្រូវការរបស់អតិថិជន។ គឺការប្រើប្រាស់បច្ចេកវិទ្យានៃការស្រាវជ្រាវអំពីការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងសវនកម្ម និងកម្រិតនៃការកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុវាយតម្លៃវិធីសាស្ត្រនៃការគ្រប់គ្រងនិងការដោះស្រាយបញ្ហាហិរញ្ញវត្ថុ ការប្រៀបធៀបការប្រើប្រាស់ជាមួយធនាគារផ្សេងៗ ឬទីផ្សារនៅក្នុងតំបន់ផ្សេងៗ ការស្រាវជ្រាវនេះអាចជួយឱ្យអ្នកសិក្សាបានយល់ដឹងកាន់តែច្បាស់អំពីសវនកម្មនៃរបាយការណ៍ហិរញ្ញវត្ថុ ថានិងមានឥទ្ធិពលលើការអភិវឌ្ឍន៍នៃវិស័យហិរញ្ញវត្ថុរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក។ និងជាការសិក្សាស្វែងយល់អំពីប្រព័ន្ធលំហូរនៃប្រតិបត្តិការហិរញ្ញវត្ថុរបស់អង្គភាពទូទៅ ឬសហគ្រាសដទៃទៀតដើម្បីទទួលបាននូវចំណេះដឹងផ្នែកសេដ្ឋកិច្ចក្នុងការធ្វើវិនិយោគទៅវិស័យហិរញ្ញប្បទាននានាផងដែល។ បន្ថែមពីនេះទៅទៀតគឺដើម្បីទទួលបានជាបទពិសោធន៍ក្នុងការងារពាក់ព័ន្ធផ្សេងៗផងដែរ។

សម្រាប់ដំណើរការនៃការសិក្សាសស្រាវជ្រាវនេះគឺឆ្លុះបញ្ចាំងរបាយការណ៍សវនកម្មហិរញ្ញវត្ថុ បញ្ជីការគណនេយ្យរបស់ធនាគារ សម្រាប់ការិយបរិច្ឆេទនាឆ្នាំ2023 នៃរបាយការណ៍ហិរញ្ញវត្ថុតែប៉ុណ្ណោះ។

## ១.៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

### ១.៥.១. វិធីសាស្ត្រស្រាវជ្រាវ

វិធីសាស្ត្រនៃការស្រាវជ្រាវ អំពីសវនកម្មរបាយការណ៍ហិរញ្ញវត្ថុរបស់ប្រព័ន្ធធនាគារគឺយើងបានចែកចេញជាច្រើនជំហាន និងវិធីសាស្ត្រដូចជាការសិក្សាមូលដ្ឋាន ការសិក្សាអំពីប្រព័ន្ធហិរញ្ញវត្ថុរបស់ធនាគារ ការសិក្សាអំពីប្រវត្តិសាស្ត្រនិងបរិបទសេដ្ឋកិច្ច គឺអាចជួយឱ្យយើងយល់ដឹងអំពីសវនកម្មនៃការប្រមូលទិន្នន័យ។ ប្រមូលទិន្នន័យពីប្រភពផ្សេងៗដូចជារបាយការណ៍ហិរញ្ញវត្ថុព័ត៌មាន អំពីរបាយការណ៍សាធារណៈ និងជាការធ្វើរបាយការណ៍ប្រចាំឆ្នាំ។ ការស្ទង់មតិអតិថិជននិងបុគ្គលិកធនាគារ ឯកសារផ្លូវការនិងសិក្សាស្រាវជ្រាវកន្លងមកវិធីសាស្ត្រគុណភាពប្រើប្រាស់ការសម្ភាសន៍ និងក្រុមផ្តោតអារម្មណ៍ដើម្បីយល់ដឹអំងពីបទពិសោធន៍នៃផ្នត់គំនិតរបស់អ្នកប្រើប្រាស់។ វិធីសាស្ត្រការគណនាប្រើប្រាស់ទិន្នន័យគណិតវិទ្យា និងស្ថិតិដើម្បីវិភាគនិងស្វែងយល់ពីទិន្នន័យដែលប្រមូលបាន។ ដើម្បីយល់ដឹងថាតើមានអ្វីខុសគ្នា និងអ្វីដែលអាចកែលម្អបានតែការរាយការណ៍និងការវិចារណារាយការណ៍លទ្ធផលនៃការស្រាវជ្រាវបានផ្តល់អនុសាសន៍ សម្រាប់ការកែលម្អនៃសវនកម្ម និងជាគោលនយោបាយផងដែរ។ វិធីសាស្ត្រទាំងនេះអាចជួយឱ្យមានការយល់ដឹងកាន់តែច្បាស់អំពីសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុ និងអាចជួយធនាគារនៅក្នុងការអភិវឌ្ឍន៍យ៉ាងមានប្រសិទ្ធភាព។

១.៥.២. វិធីសាស្ត្រប្រមូលទិន្នន័យ

- ទិន្នន័យទី១៖ នៃការសិក្សាស្រាវជ្រាវរបស់ខ្ញុំបាទគឺ បានផ្អែកលើការស្វែងរកទៅលើគេហៈទំព័ររបស់ **Website:wooribank.com.kh** នៃធនាគារ អ៊ូរី (ខេមបូឌា) ម.ក ដែលជារបាយការណ៍នៃការបានធ្វើសវនកម្មហិរញ្ញវត្ថុសម្រាប់ឆ្នាំ2023 ដែលជារបាយការណ៍សវនករឯករាជ្យ **KPMG** Cambodia Ltd.
- ទិន្នន័យទី២៖ គឺជាការស្រាវជ្រាវទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ឬអង្គភាពសេវាកម្មផ្នែកហិរិញ្ញវត្ថុផ្សេងទៀតគឺដើម្បីជាការប្រៀបធៀបគ្នា ទៅលើសេវាកម្មប្រហាក់ប្រហែលក្នុងការប្រមូលបទពិសោធន៍ថ្មីៗសម្រាប់អភិវឌ្ឍន៍គោលនយោបាយណ៍ និងនិតិវិធីរបាយការណ៍របស់ខ្លួនឱ្យបានប្រសើរ
- វិធីសាស្ត្រវិភាគទិន្នន័យ៖ជាការវិភាគទិន្នន័យគឺធ្វើឡើងដោយពឹកផ្អែកទាំងស្រុងនូវរាល់ឯកសារដែលប្រមូលបាន និងឯកសារដែលមានស្រាប់ដើម្បីជាជំនួយដល់ការវិភាគលើរបាយការណ៍ទាំងនេះ។

## ១.៦. សារៈសំខាន់នៃការស្រាវជ្រាវ

ជាការពិតណាស់រាល់កិច្ចការស្រាវជ្រាវអំពីរបាយការណ៍សវនកម្មហិរញ្ញវត្ថុរបស់ធនាគារគឺ៖មានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ធនាគារ,សម្រាប់សង្គមជាតិនិងសម្រាប់អ្នកស្រាវជ្រាវផងដែរដោយសារតែបញ្ហានៅក្នុងវិស័យហិរញ្ញវត្ថុអាចមានផលប៉ះពាល់ធ្ងន់ធ្ងរនិងបានជ្រៀបចូលយ៉ាងសំខាន់ក្នុងប្រព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុន, សង្គមជាតិហើយនិងអ្នកស្រាវជ្រាវ។ដោយខាងក្រោមនេះជាសារៈសំខាន់នៃការស្រាវជ្រាវមួយចំនួនគឺ៖

**ចំពោះធនាគារឬអង្គភាពគឺ៖**កិច្ចការស្រាវជ្រាវគឺអាចជួយបង្កើតឱ្យបរិយាកាសដែលមានភាពជឿជាក់ច្បាស់សម្រាប់អ្នកវិនិយោគ និងសហគ្រាសក្នុងការវិនិយោគនិងអភិវឌ្ឍន៍សេដ្ឋកិច្ច។ ការស្រាវជ្រាវក៏អាចជួយក្រុមហ៊ុនក្នុងការកំណត់និងគ្រប់គ្រងហានិភ័យដែលអាចនឹងកើតមានឡើងពីការប្រែប្រួលនៃស្ថានភាពហិរញ្ញវត្ថុនិងជាគោលនយោបាយណ៍សេដ្ឋកិច្ច។

**ចំពោះសង្គមជាតិគឺ៖**ការអនុវត្តន៍ការស្រាវជ្រាវអំពីសវនកម្មអាចធ្វើឱ្យសង្គមមានភាពត្រជាក់ស្រួលទៅលើការគ្រប់គ្រងហិរញ្ញវត្ថុ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ ការស្រាវជ្រាវអាចជួយក្រុមហ៊ុននិងសង្គមជាតិក្នុង

ការបង្កើតជាយុទ្ធសាស្ត្រដែលមានភាពច្បាស់លាស់ដើម្បីត្រៀមខ្លួនសម្រាប់ការប្រែប្រួលនៃទីផ្សារ និងពីស្ថានភាពផ្នែកប្រព័ន្ធហិរញ្ញវត្ថុទូទៅផងដែរ។

**ចំពោះអ្នកស្រាវជ្រាវគឺ៖** ការបង្កើនការយល់ដឹងការយល់ដឹងអំពី របាយការណ៍សវនកម្មហិរញ្ញវត្ថុអាចដែលអាចមានឥទ្ធិពលលើការអភិវឌ្ឍន៍ទៅលើនាយកដ្ឋាននិងជាការអភិវឌ្ឍន៍យុទ្ធសាស្ត្ររបស់ពួកគេ គឺក្នុងការវិនិយោគទន់គឺ នៅពេលដែលអ្នកស្រាវជ្រាវបានយល់ដឹងច្បាស់អំពីរបាយការណ៍ហិរញ្ញវត្ថុមួយជាក់លាក់និងត្រឹមត្រូវក្នុងការផ្សព្វផ្សាយចំណេះដឹង និងបទពិសោធន៍ផ្នែកហិរញ្ញវត្ថុឱ្យបានទូលំទូលាយសម្រាប់វិនិយោគ។

*ជាការកត់សំគាល់៖*

ការស្រាវជ្រាវអំពីរបាយការណ៍សវនកម្មហិរញ្ញវត្ថុគឺជាគន្លងដ៏សំខាន់សម្រាប់ការអភិវឌ្ឍន៍ដ៏ល្អប្រសើរនៅក្នុងសហគមន៍ និងសេដ្ឋកិច្ច គឺវាជួយឱ្យមានការយល់ដឹង និងការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀតគឺម្រាប់បំរើការជូនទៅសាធារណៈជនទាំងមូលមិនថាត្រឹមតែសម្រាប់អង្គភាពសហគ្រាសសង្គមជាតិ ឬសម្រាប់អ្នកស្រាវជ្រាវប៉ុណ្ណោះឡើយគឺជាទូទៅគ្រប់វិស័យទាំងអស់ត្រូវតែយល់ពីរបាយការណ៍។

## ១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវគឺត្រូវបានចែកចេញជា ៥ ជំពូកដូចខាងក្រោម៖

**ជំពូកទី១៖** សេចក្តីផ្តើមខាងលើគឺខ្ញុំបាទបានកំណត់គោលការណ៍ចំនួន៥ចំណុចធំៗ រួមមានដូចជា៖ លំនាំបញ្ហានៃការស្រាវជ្រាវ, ចំណោទបញ្ហានៃការស្រាវជ្រាវ, គោលបំណងនៃការស្រាវជ្រាវ, ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ។ ដើម្បីឈានទៅដល់ការសិក្សាស្រាវជ្រាលើរបាយការណ៍សវនកម្មឯករាជ្យរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ទាំងមូលបាន គឺខ្ញុំបានកំណត់នូវជំពូកផ្សេងៗទៀតចំនួន៤ ដូចតទៅនេះ៖

**ជំពូកទី២៖** គឺសវនកម្មរបស់ក្រុមហ៊ុនសវនករឯករាជ្យទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អ៊ីរីទាំងមូលតែម្តង។ ដោយធ្វើការសិក្សាតាមផ្នែកនៃនិតិវិធីរួមមាន៖ និយមន័យនិងទ្រឹស្តីពាក់ព័ន្ធជាមួយប្រធានបទ, និយមន័យរបស់ធនាគារ, ប្រវត្តិរបស់ធនាគារ និងប្រភេទរបស់ធនាគារផងដែរ។ មិនតែប៉ុណ្ណោះគឺជាការនិយាយអំពីនិតិវិធីនិងវិធីសាស្ត្រក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុទូទៅតែម្តង។

**ជំពូកទី៣៖** លទ្ធផលនៃការស្រាវជ្រាវគឺជាការលើកឡើងអំពីស្ថានភាពទូទៅរបស់អង្គភាពដូចជាប្រវត្តិរបស់អង្គភាពដូចជា៖បេសកកម្មទ,ស្សនវិស័យ,រចនាសម្ព័ន្ធចាត់តាំង (តួនាទី និងភារកិច្ច) និងបន្ទាប់មកត្រូវលើកឡើងពីវិធីសាស្ត្រនិងនិតិវិធីរបស់សវនករផ្ទៃក្រៅក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ។

**ជំពូកទី៤៖** ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយគឺវិភាគទៅលើចំណុចទាំងអស់ដែលត្រូវបានអនុវត្តជាក់ស្តែង (គឺគ្រប់ចំណុចទាំងអស់ដែលមាននៅក្នុងជំពូកទី៣)ក្នុងគោលបំណង វិភាគអោយឃើញនូវចំណុចខ្វះខាតទាំងឡាយដើម្បីធ្វើការកែលម្អនិងអភិវឌ្ឍន៍រាល់ចំណុចខ្វះខាតទាំងនោះផងដែរ។

**ជំពូកទី៥៖** សេចក្តីសន្និដ្ឋាននិងការផ្តល់អនុសាសន៍គឺជាការសិន្និដ្ឋានទៅលើគ្រប់ចំណុចទាំងអស់និងផ្តល់ជាយោបល់ អនុសាសន៍ទៅលើចំណុចដែលត្រូវកែលម្អដើម្បីជាភាពជោគជ័យជានិរន្តរបស់ធនាគារ។

# ជំពូកទី២
# សវនកម្មឯករាជ្យលើរបាយការណ៍ហិរញ្ញវត្ថុ

## ២.១. ស្ថានភាពទូទៅលើរបាយការណ៍សវនកម្មហិរញ្ញវត្ថុរបស់ធនាគារ

គឺជាកិច្ចការដែលក្រុមសវនករធ្វើការពិនិត្យវិនិច្ឆ័យអំពីគោលការណ៍ទូទៅរបស់ពួកគេជារបៀបបែបបទវិៈទៅលើការងារដែលពាក់ព័ន្ធផ្នែកហិរញ្ញវត្ថុ និងប៉ាន់ស្មានលើទិន្នន័យហិរញ្ញវត្ថុរបស់ធនាគារ ឬអង្គភាពមួយដើម្បីយល់ពីសុខុមាលភាពហិរញ្ញវត្ថុ និងការប្រតិបត្តិរបស់អាជីវកម្មក៏ដូចជាលក្ខណៈទូទៅនៃការវិភាគទៅលើរបាយការណ៍ហិរញ្ញវត្ថុ និងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុផងដែរ។

របាយការណ៍ហិរញ្ញវត្ថុទាំងនោះរួមមាន តារាងតុល្យការ(របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ) របាយការណ៍ការប្រាក់ចំណូល(ត្រូវបានគេស្គាល់ផងដែរថាជារបាយការណ៍ប្រាក់ចំណេញនិងការបាត់បង់) និងរបាយការណ៍លំហូរសាច់ប្រាក់។ របាយការណ៍ទាំងនេះផ្តល់នូវទិដ្ឋភាពទូទៅនៃសុខភាពហិរញ្ញវត្ថុ ប្រតិបត្តិការ និងទីតាំងសាច់ប្រាក់របស់ធនាគារ។

### ២.១.១. និយមន័យរបស់ធនាគារ

ធនាគារគឺជាគ្រឹះស្ថានហិរញ្ញវត្ថុដែលទទួលយកប្រាក់បញ្ញើពីសាធារណជននិងបង្កើតប្រាក់បញ្ញើតាមតម្រូវការក្នុងពេលដំណាលគ្នាធ្វើកម្ចី។ សកម្មភាពផ្តល់ប្រាក់កម្ចីអាចត្រូវបានអនុវត្តដោយផ្ទាល់ដោយធនាគារ ឬដោយប្រយោលតាមរយៈទីផ្សារមូលធន។

ដោយសារធនាគារដើរតួនាទីយ៉ាងសំខាន់ក្នុងស្ថិរភាពហិរញ្ញវត្ថុ និងសេដ្ឋកិច្ចរបស់ប្រទេសមួយ យុត្តាធិការភាគច្រើនអនុវត្តបទប្បញ្ញត្តិកម្រិតខ្ពស់លើធនាគារ។ ប្រទេសភាគច្រើនបានបង្កើតប្រព័ន្ធមួយដែលគេស្គាល់ថាជាធនាគារបម្រុងប្រភាគដែលធនាគារកាន់កាប់ទ្រព្យសកម្មរាវស្មើនឹងតែផ្នែកមួយនៃបំណុលបច្ចុប្បន្នរបស់ពួកគេ។ បន្ថែមពីលើបទប្បញ្ញត្តិផ្សេងទៀតដែលមានបំណងធានាសាច់ប្រាក់ងាយស្រួលដោយធនាគារជាទូគឺទៅត្រូវទទួលរងនូវតម្រូវការដើមទុនអប្បបរមាដោយផ្អែកលើស្តង់ដារមូលធនអន្តរជាតិដែលជាកិច្ចព្រមព្រៀង។

ដោយនៅក្នុងន័យទំនើបធនាគារ គឺត្រូវបានវិវត្តនៅក្នុងសតវត្សទីដប់បួន នៅក្នុងទីក្រុងដ៏រុងរឿងនៃក្រុមហ៊ុន Renaissance ប្រទេសអ៊ីតាលី ប៉ុន្តែតាមវិធីជាច្រើនបានដំណើរការជាការបន្តនៃគំនិត និងគំនិតនៃឥណទាន និងការផ្តល់ប្រាក់កម្ចីដែលមានឫសគល់នៅក្នុងពិភពបុរាណ[1] ។

### ២.១.២. ប្រវត្តិរបស់ធនាគារ

ប្រវត្តិសាស្ត្រនៃធនាគារគឺ បានចាប់ផ្តើមជាមួយនឹងធនាគារគំរូដំបូងពោលគឺពាណិជ្ជករនៃពិភពលោកដែលបានផ្តល់ប្រាក់កម្ចីគ្រាប់ធញ្ញជាតិដល់កសិករ និងពាណិជ្ជករដែលដឹកជញ្ជូនទំនិញមកទីក្រុង។ ដោយវាគឺប្រហែលឆ្នាំ 2000 មុនគ.ស. នៅអាសស៊ើរ ឥណ្ឌា និងស៊ូមឺរ (Assyria, India and Sumer)។ ក្រោយមក នៅប្រទេសក្រិចបុរាណ និងក្នុងកំឡុងចក្រភពរ៉ូម អ្នកផ្តល់ប្រាក់កម្ចីដែលមានមូលដ្ឋាននៅប្រាសាទនានាបានផ្តល់ប្រាក់កម្ចីខណៈពេលដែលទទួលយកប្រាក់បញ្ញើ និងធ្វើការផ្លាស់ប្តូរជាប្រាក់។ បុរាណវិទ្យាពីសម័យកាលនេះនៅក្នុងប្រទេសចិនបុរាណ និងឥណ្ឌាក៏បង្ហាញភស្តុតាងនៃការខ្ចីប្រាក់ផងដែរ។

អ្នកប្រាជ្ញជាច្រើនបានតាមដានឫសគល់ប្រវត្តិសាស្ត្រនៃប្រព័ន្ធធនាគារទំនើបដល់មជ្ឈិមសម័យ និងក្រុមហ៊ុន Renaissance ប្រទេសអ៊ីតាលី ជាពិសេសទីក្រុងដ៏សំបូរបែបនៃ Florence, Venice និង Genoa។ គ្រួសារ Bardi និង Peruzzi បានគ្រប់គ្រងធនាគារនៅ Florence សតវត្សទី១៤ ដោយបានបង្កើតសាខានៅក្នុងតំបន់

ជាច្រើនទៀតនៃទ្វីបអឺរ៉ុប។ ហើយធនាគារអ៊ីតាលីដ៏ល្បីល្បាញបំផុតគឺធនាគារMedici ដែលបង្កើតឡើងដោយ Giovanni Medici ក្នុងឆ្នាំ1397។ ធនាគារចាស់ជាងគេដែលនៅមានស្រាប់គឺ Banca Monte dei Paschi di Siena ដែលមានទីស្នាក់ការនៅ Siena ប្រទេសអ៊ីតាលី ដែលបានដំណើរការជាបន្តបន្ទាប់គឺតាំងពីឆ្នាំ 1472 រហូតមកដល់ចុងឆ្នាំ2002 ធនាគារចាស់ជាងគេដែលនៅតែដំណើរការគឺ Banco di Napoli ដែលមានទីស្នាក់ការនៅទីក្រុង Naples ប្រទេសអ៊ីតាលី ដែលបានដំណើរការតាំងពីឆ្នាំ 1463។

ការអភិវឌ្ឍន៍នៃធនាគារបានរីករាលដាលពីភាគខាងជើងប្រទេសអ៊ីតាលីទូទាំងចក្រភពរ៉ូមបរិសុទ្ធ នៅសតវត្សទី 15 និងទី 16 ទៅកាន់អឺរ៉ុបខាងជើង។ នេះត្រូវបានបន្តដោយការច្នៃប្រឌិតសំខាន់ៗមួយចំនួនដែលបានកើតឡើងនៅទីក្រុង Amsterdam ក្នុងអំឡុងសាធារណរដ្ឋហូឡង់ក្នុងសតវត្សទី 17 និងនៅទីក្រុងឡុងដ៍ចាប់តាំងពីសតវត្សទី 18 ។ ក្នុងកំឡុងសតវត្សទី 20 ការអភិវឌ្ឍន៍ផ្នែកទូរគមនាគមន៍ និងកុំព្យូទ័របានបណ្តាលឱ្យមានការផ្លាស់ប្តូរយ៉ាងសំខាន់ចំពោះប្រតិបត្តិការរបស់ធនាគារហើយអនុញ្ញាតឱ្យធនាគារកើនឡើងយ៉ាងខ្លាំងនូវទំហំ និងការរីករាលដាលភូមិសាស្ត្រ។ វិបត្តិហិរញ្ញវត្ថុឆ្នាំ 2008 បាននាំឱ្យមានការបរាជ័យរបស់ធនាគារជាច្រើន រួមទាំងធនាគារធំៗមួយចំនួនរបស់ពិភពលោក និងបានបង្កឱ្យមានការជជែកវែកញែកជាច្រើនអំពីបទប្បញ្ញត្តិនៃធនាគារផងដែរ [2]។

### ២.១.៣. ប្រភេទធនាគារ

មានធនាគារជាច្រើនប្រភេទដែលបានបែងចែកយ៉ាងទូលំទូលាយដូចជា ធនាគារកណ្តាល ធនាគារពាណិជ្ជ និងធនាគារឯកទេស។ ធនាគារពាណិជ្ជគឺជាធម្មតាផ្តល់សេវាកម្មដូចជាប្រាក់បញ្ញើ ប្រាក់កម្ចី និងប្រតិបត្តិការហិរញ្ញវត្ថុដល់បុគ្គលនិងអាជីវកម្ម។ ប្រភេទផ្សេងទៀតរួមមានធនាគារសហករណ៍ ធនាគារជនបទក្នុងតំបន់ និងតាមអ៊ីនធឺណិត/neobanks។

ដោយខាងក្រោមនេះគឺជាការវិភាគលម្អិតបន្ថែមទៀតរបស់ប្រតិបត្តិការរបស់ធនាគារទៅតាមគោលការណ៍៖

**ធនាគារកណ្តាល៖** គឺជាធនាគារកម្រិតកំពូលក្នុងប្រទេសមួយ ឬក្រុមប្រទេសមួយ ដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងការផ្គត់ផ្គង់ប្រាក់ ត្រួតពិនិត្យធនាគារពាណិជ្ជ និងការអនុវត្តគោលនយោបាយរូបិយវត្ថុ។ ប្រព័ន្ធ Federal Reserve នៅសហរដ្ឋអាមេរិកគឺជាឧទាហរណ៍មួយ។

**ធនាគារពាណិជ្ជ៖**គឺជាប្រភេទធនាគារទូទៅបំផុត ដែលផ្តល់សេវាកម្មដូចជា គណនីពិនិត្យ និងសន្សំ ប្រាក់កម្ចីនិងប័ណ្ណឥណទាន។ គឺថាពួកគេអាចត្រូវបានចាត់ថ្នាក់បន្ថែមទៀតទៅជាធនាគារវិស័យសាធារណៈ ធនាគារវិស័យឯកជន និងធនាគារបរទេស។

**ធនាគារឯកទេស៖**ធនាគារទាំងនេះផ្តោតលើប្រភេទធនាគារជាក់លាក់ ឬផ្នែកអតិថិជន។ ឧទាហរណ៍រួមមាន ធនាគារសហករណ៍ស្ថាប័នមិនរកប្រាក់ចំណេញដែលជាកម្មសិទ្ធិ និងដំណើរការដោយសមាជិករបស់ពួកគេ ជារឿយៗផ្តល់លក្ខខណ្ឌអំណោយផល។ ធនាគារជនបទក្នុងតំបន់ (RRB) គឺផ្តោតលើការបម្រើតំបន់ជនបទនិងកសិករ។ ធនាគារអភិវឌ្ឍន៍សហគមន៍គឺមានគោលបំណងផ្តល់សេវាហិរញ្ញវត្ថុដល់សហគមន៍ដែលខ្វះខាត។ ធនាគារវិនិយោគផ្តោតលើសកម្មភាពដូចជាការធានាទិញមូលបត្រនិងការរួមបញ្ចូលគ្នា និងការទិញយក [3]។

## ២.២. វិធីសាស្រ្ត និងនីតិវិធីសម្រាប់សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

វិធីសាស្រ្តនិងនីតិវិធី សម្រាប់សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុគឺពាក់ព័ន្ធនឹងដំណើរការជាប្រព័ន្ធនៃការពិនិត្យលើកំណត់ត្រាហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដើម្បីធានាថាពួកវាត្រូវបានបង្ហាញដោយយុត្តិធម៌និងស្របទៅតាមស្តង់ដារគណនេយ្យ។ គឺសវនករប្រើបច្ចេកទេសផ្សេងៗដើម្បីប្រមូលភស្តុតាង និងបង្កើតមតិលើភាពត្រឹមត្រូវនិងភាពជឿជាក់នៃរបាយការណ៍ហិរញ្ញវត្ថុ។

### ២.២.១. និយមន័យរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុនៅក្នុងគណនេយ្យគឺជាកំណត់ត្រាជាលាយលក្ខណ៍អក្សរដែលបង្ហាញពីសកម្មភាពរូបិយវត្ថុនិងដំណើរការនៃមុខតំណែងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។វារៀបរាប់លម្អិតអំពីព័ត៌មានសំខាន់ៗអំពីអ្វីដែលអង្គភាពជាម្ចាស់ និងជំពាក់ ព្រមទាំងចំនួនប្រាក់ដែលខ្លួនបានធ្វើ និងចំណាយ។

គណនេយ្យករនិងអ្នកវិនិយោគ តែងតែធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងហិរញ្ញវត្ថុ ឬការវិនិយោគ។ ភ្នាក់ងាររដ្ឋាភិបាលក៏អាចធ្វើសវនកម្មលើសុខភាពហិរញ្ញវត្ថុរបស់អាជីវកម្មដើម្បីធានាបាននូវភាពត្រឹមត្រូវ និងការអនុលោមតាមច្បាប់[4]។

### ២.២.២. ប្រវត្តិរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុដែលមិនអាចខ្វះបានសម្រាប់អាជីវកម្មនិងការវិនិយោគទំនើប គឺវាមានប្រវត្តិដ៏សម្បូរបែប និងយូរអង្វែងដោយវិវត្តន៍ពីកំណត់ត្រាសាមញ្ញនៃប្រតិបត្តិការកសិកម្មទៅជារបាយការណ៍ស្តង់ដារស្មុគស្មាញដែលយើងឃើញសព្វថ្ងៃនេះ។ ការអភិវឌ្ឍន៍របស់ពួកគេគឺជារឿងដែលជាប់ពាក់ព័ន្ធជាមួយនឹងការរីកចម្រើននៃពាណិជ្ជកម្ម ការកើនឡើងនៃសាជីវកម្ម និងការកើនឡើងតម្រូវការសម្រាប់តម្លាភាពសិក្សា និងគណនេយ្យភាពនៅក្នុងពិភពសេដ្ឋកិច្ច។ ដើមកំណើតបុរាណ ឫសគល់ ដំបូងបំផុតនៃការរក្សាកំណត់ត្រាលើហិរញ្ញវត្ថុអាចត្រូវបានគេតាមដានរាប់ពាន់ឆ្នាំទៅ Mesopotamia បុរាណ។ នៅដើម 7,000 ឆ្នាំមុន អរិយធម៌នៅអឌ្ឍចន្ទមានជីជាតិបានប្រើគ្រាប់ដីឥដ្ឋដើម្បីកត់ត្រាការដោះដូរទំនិញដូចជាដំណាំ និងបសុសត្វ។ កំណត់ត្រាជាមូលដ្ឋានទាំងនេះបានបម្រើជាទម្រង់នៃកិច្ចសន្យា និងគឺជាមធ្យោបាយមួយដើម្បីតាមដានកាតព្វកិច្ច។ ស្រដៀងគ្នានេះដែរជនជាតិអេស៊ីបបុរាណនិងរ៉ូមបានរក្សាកំណត់ត្រាលម្អិតសម្រាប់ការគ្រប់គ្រងពន្ធត្រួតពិនិត្យគម្រោងសាធារណៈ និងតាមដានទ្រព្យសម្បត្តិរបស់រដ្ឋ។

ពេលវេលាដ៏សំខាន់នៅក្នុងប្រវត្តិសាស្រ្តនៃគណនេយ្យបានមកដល់នៅក្នុងសតវត្សទី 15 គឺជាមួយនឹងការងាររបស់ហ្វ្រង់ស៊ីស្កា និងគណិតវិទូជនជាតិអ៊ីតាលី Luca Pacioli ។ ជារឿយៗត្រូវបានគេសរសើរថាជា **"បិតានៃគណនេយ្យទំនើប"** Pacioli មិនបានបង្កើតការកត់ត្រាចូលពីរជងទេ ប៉ុន្តែគាត់គឺជាមនុស្សដំបូងគេដែលធ្វើកូដកម្មនិងផ្សព្វផ្សាយប្រព័ន្ធនេះយ៉ាងទូលំទូលាយនៅក្នុងសន្និសញ្ញាឆ្នាំ 1494 របស់គាត់ "Summa de Arithmetica, Geometria, Proportioni et Proportionalita" ។

ប្រព័ន្ធចូលទ្វេរជងរបស់ Pacioli ជាមួយនឹងគោលការណ៍ជាមូលដ្ឋានរបស់វាថា សម្រាប់រាល់ឥណពន្ធត្រូវតែមានឥណទានដែលត្រូវគ្នា គឺបានផ្តល់ទិដ្ឋភាពដ៏ទូលំទូលាយ និងមានតុល្យភាពនៃទីតាំងហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមួយ។ ការបង្កើតថ្មីនេះបានបង្កើតមូលដ្ឋានគ្រឹះនៃគំនិតសម្រាប់តារាងតុល្យការទំនើប ដែលអនុញ្ញាតឱ្យពាណិជ្ជករមើលឃើញភ្លាមៗនូវអ្វីដែលពួកគេមាន (ទ្រព្យសកម្ម) និងអ្វីដែលពួកគេជំពាក់ (បំណុល)។

ការកើនឡើងនៃសាជីវកម្មនិងកំណើតនៃសេចក្តីថ្លែងការណ៍ទំនើបបដិវត្តន៍ឧស្សាហកម្មនៅសតវត្ស

ទី 18 និងទី 19 បានជំរុញកំណើននៃសហគ្រាសខ្នាតធំដែលមានអ្នកវិនិយោគច្រើន។ នេះបានបង្កើតនូវភាពស្វាហាប់ថ្មីមួយដែលម្ចាស់ (ម្ចាស់ភាគហ៊ុន) ជារឿយៗវាគឺដាច់ដោយឡែកពីអ្នកគ្រប់គ្រងដែលដំណើរការក្រុមហ៊ុន។ ការបំបែកនេះទាមទារឱ្យមានវិធីផ្លូវការ និងតម្លាភាពបន្ថែមទៀតក្នុងការរាយការណ៍អំពីការអនុវត្តរបស់ក្រុមហ៊ុន និងសុខភាពហិរញ្ញវត្ថុ។

នៅឆ្នាំ 1987 ក្រុមប្រឹក្សាស្តង់ដារគណនេយ្យហិរញ្ញវត្ថុ (FASB) នៅសហរដ្ឋអាមេរិកបានបញ្ជាឱ្យដាក់បញ្ចូលរបាយការណ៍នៃលំហូរសាច់ប្រាក់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។នៅពេលដែលអាជីវកម្មបានក្លាយជាសកលកាន់តែខ្លាំងឡើង តម្រូវការសម្រាប់សំណុំស្តង់ដារគណនេយ្យអន្តរជាតិទូទៅបានក្លាយជាភស្តុតាង។ នេះបាននាំឱ្យមានការបង្កើតគណៈកម្មាធិការស្តង់ដារគណនេយ្យអន្តរជាតិ (IASC) ក្នុងឆ្នាំ 1973 ដែលក្រោយមកត្រូវបានទទួលជោគជ័យដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ (IASB) ក្នុងឆ្នាំ 2001។ IASB បង្កើត និងផ្សព្វផ្សាយស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) ដែលឥឡូវនេះត្រូវបានប្រើប្រាស់នៅក្នុងប្រទេសជាង 140 ប្រទេស។

យុគសម័យឌីជីថល និងអនាគតនៃរបាយការណ៍ហិរញ្ញវត្ថុការមកដល់នៃកុំព្យូទ័រ និងកម្មវិធីគណនេយ្យបានផ្លាស់ប្តូរការរៀបចំ និងការវិភាគរបាយការណ៍ហិរញ្ញវត្ថុ ធ្វើឱ្យដំណើរការកាន់តែលឿន ត្រឹមត្រូវ និងអាចចូលដំណើរការបានកាន់តែច្រើន។ សព្វថ្ងៃនេះវិនិយោគិន និងអ្នកវិភាគអាចចូលប្រើទិន្នន័យហិរញ្ញវត្ថុដ៏សម្បូរបែបនៅចុងម្រាមដៃរបស់ពួកគេ ដែលអនុញ្ញាតឱ្យមានការវិភាគ និងការសម្រេចចិត្តកាន់តែទំនើប [5]។

**២.២.៣. សមាសធាតុរបាយការណ៍ហិរញ្ញវត្ថុ**

របាយការណ៍ហិរញ្ញវត្ថុ (ឬរបាយការណ៍គណនេយ្យ) គឺជាកំណត់ត្រាផ្លូវការនៃសកម្មភាពហិរញ្ញវត្ថុ និងទីតាំងរបស់អាជីវកម្មបុគ្គល ឬអង្គភាពផ្សេងទៀត។ គឺព័ត៌មានហិរញ្ញវត្ថុដែលពាក់ព័ន្ធត្រូវបានបង្ហាញក្នុងលក្ខណៈរចនាសម្ព័ន្ធនិងជាទម្រង់ដែលងាយយល់។ ជាធម្មតាពួកវារួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុមូលដ្ឋានចំនួនបួនអមដោយការពិភាក្សា និងការវិភាគអំពីការគ្រប់គ្រង៖

ក). តារាងតុល្យការរាយការណ៍៖ បង្ហាញអំពីទ្រព្យសកម្ម បំណុល និងសមធម៌របស់ម្ចាស់ក្រុមហ៊ុននៅចំណុចដែលបានកំណត់ក្នុងពេលវេលា។

ខ). របាយការណ៍ប្រាក់ចំណូល៖ រាយការណ៍អំពីប្រាក់ចំណូល ការចំណាយ និងប្រាក់ចំណេញរបស់ក្រុមហ៊ុនក្នុងរយៈពេលដែលបានបញ្ជាក់។ គឺថារបាយការណ៍ប្រាក់ចំណេញនិងការបាត់បង់ផ្តល់ព័ត៌មានអំពីប្រតិបត្តិការរបស់សហគ្រាស។ ទាំងនេះរួមបញ្ចូលការលក់ និងការចំណាយផ្សេងៗដែលកើតឡើងក្នុងអំឡុងពេលដែលបានកំណត់។ សេចក្តីថ្លែងការណ៍នៃការផ្លាស់ប្តូរនៅក្នុងរបាយការណ៍សមធម៌ស្តីពីការផ្លាស់ប្តូរភាគហ៊ុនរបស់ក្រុមហ៊ុនក្នុងរយៈពេលដែលបានបញ្ជាក់។

គ). របាយការណ៍លំហូរសាច់ប្រាក់៖ គឺរាយការណ៍អំពីសកម្មភាពលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនជាពិសេសសកម្មភាពប្រតិបត្តិការ ការវិនិយោគ និងហិរញ្ញវត្ថុក្នុងរយៈពេលដែលបានកំណត់។

ឃ). របាយការណ៍នៃការផ្លាស់ប្តូរភាគហ៊ុន និងរបាយការណ៍លំហូរសាច់ប្រាក់នីមួយៗវាគឺតំណាងឱ្យសកម្មភាពក្នុងរយៈពេលគណនេយ្យ។ នៅក្នុងតារាងតុល្យការ ម្ចាស់អាជីវកម្ម និងអ្នកជំនាញផ្នែកហិរញ្ញវត្ថុអាចធ្វើការសម្រេចចិត្តប្រកបដោយព័ត៌មានដែលជំរុញឱ្យមានកំណើន និងស្ថិរភាព[6]។

## ២.៣. ផលប្រយោជន៍នៃការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

សវនកម្មនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដោយគណនេយ្យករសាធារណៈដែលមានការបញ្ជាក់ឯករាជ្យ(CPA)គឺច្រើនជាងទម្រង់បទប្បញ្ញត្តិទៅទៀត។ វាគឺជាដំណើរការដ៏សំខាន់មួយដែលបានផ្តល់នូវអត្ថប្រយោជន៍យ៉ាងសំខាន់ ជាក់ស្តែងដល់ក្រុមហ៊ុនខ្លួនឯង ក៏ដូចជាចំពោះភាគីពាក់ព័ន្ធខាងក្រៅដ៏ធំទូលាយផងដែរ។ គោលបំណងស្នូលនៃសវនកម្មគឺដើម្បីផ្តល់នូវមតិឯករាជ្យនិងគោលបំណងថាតើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានបង្ហាញដោយស្មើភាពក្នុងគ្រប់រូបភាព ស្របតាមក្របខ័ណ្ឌរបាយការណ៍ហិរញ្ញវត្ថុដែលបានបញ្ជាក់ដូចជាគោលការណ៍គណនេយ្យដែលទទួលយកជាទូទៅ (GAAP) ឬស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) ដែរឬទេ។ ការផ្ទៀងផ្ទាត់ឯករាជ្យនេះដោះសោអត្ថប្រយោជន៍ជាច្រើន បង្កើនទំនុកចិត្តតម្លាភាព និងប្រសិទ្ធភាពប្រតិបត្តិរបស់សវនករឯករាជ្យផងដែរ [7]។

### ២.៣.១. និយមន័យសវនកម្ម

សវនកម្ម (Audit) គឺជាដំណើរការដែលត្រូវបានអនុវត្តដើម្បីពិនិត្យ និងវាយតម្លៃស្ថានភាពហិរញ្ញវត្ថុ និងប្រព័ន្ធគ្រប់គ្រងរបស់អង្គភាព ឬក្រុមហ៊ុន។ ដំណើរការនេះអាចមានលក្ខណៈដូចជា៖ ការពិនិត្យសវនកម្មពិនិត្យពីគុណភាព និងសុវត្ថិភាពនៃការប្រើប្រាស់ធនធាន ហើយពិនិត្យអំពីការចំណាយ និងចំណូល។ ការប្រាប់បញ្ជាក់វាប្រើប្រាស់ការប្រាប់បញ្ជាក់ពីរាយការណ៍ហិរញ្ញវត្ថុ ដើម្បីធ្វើឱ្យមានភាពច្បាស់លាស់ និងទំនុកចិត្តលើទិន្នន័យ។ ការវាយតម្លៃសវនកម្មអាចវាយតម្លៃផលប៉ះពាល់នៃគោលនយោបាយនិងការប្រតិបត្តិការណ៍ដើម្បីសម្រេចបាននូវការកែលម្អ។ ការផ្តល់យោបល់បន្ទាប់ពីការពិនិត្យ និងវាយតម្លៃ អ្នកសវនកម្មអាចផ្តល់យោបល់សម្រាប់ការកែលម្អ និងការគ្រប់គ្រងប្រព័ន្ធ។ សវនកម្មមានសារៈសំខាន់ក្នុងការប្រាប់បញ្ជាក់ពីភាពសុវត្ថិភាព និងភាពត្រឹមត្រូវនៃព័ត៌មានហិរញ្ញវត្ថុដែលជាកត្តាសំខាន់សម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍន៍ក្នុងអង្គភាព សហគ្រាស ក្រុមហ៊ុន រួមទាំងប្រព័ន្ធធនាគារផងដែរ។

ដូច្នេះនិយមន័យសវនកម្មសវនកម្មត្រូវបានកំណត់ថាគឺជាដំណើរការនៃការតាមដាននិងឆែកឆេរប្រមូលនូវភស្តុតាងសវនកម្មទៅលើការជានាអះអាងអំពីព្រឹត្តិការណ៍និងសកម្មភាពសេដ្ឋកិច្ចដើម្បីបញ្ជាក់ឱ្យឃើញនូវកម្រិតឆ្លើយតបរវាងការអះអាងរបស់អ្នកគ្រប់គ្រង និងលក្ខណៈវិនិច្ឆ័យដែលបង្កើតឡើងហើយចុងក្រោយការផ្សព្វផ្សាយនូវលទ្ធផលនេះទៅអ្នកប្រើប្រាស់ដែលពាក់ព័ន្ធ [8]។

### ២.៣.២. ប្រវត្តិ នៃសវនកម្ម

តាមពិតទៅប្រវត្តិនៃសវនកម្ម(Audit)មិនត្រឹមតែមានប្រភពពីសម័យថ្មីទេប៉ុន្តែវាមានប្រវត្តិក្នុងអនុកាលយ៉ាងយូរមកហើយ។ ដោយឡែកខាងក្រោមនេះខ្ញុំនឹងធ្វើការពិពណ៌នាខ្លះៗ ពីការអភិវឌ្ឍន៍នៃសវនកម្មសម្រាប់ដំណាក់កាលនិមួយៗដូចតទៅ៖

អេហ្ស៊ីបនិងប៉េរ៉សគឺ ការពិនិត្យហិរញ្ញវត្ថុមានប្រភពមកពីសម័យបុរាណដែលបានប្រព្រឹត្តក្នុងអេហ្ស៊ីបនិងប៉េរ៉សត្រូវបានប្រើប្រាស់ក្នុងការគ្រប់គ្រងធនធាននិងចំណូលពីការចែកចាយសកម្មភាពហិរញ្ញវត្ថុ។

សម័យមជ្ឈមណ្ឌលម៉ាស៊ីនគណនាដំបូងនៃការអភិវឌ្ឍន៍ម៉ាស៊ីនគណនាដំបូងនៅក្នុងសម័យមជ្ឈមណ្ឌលបានបានបង្កើនសមត្ថភាពក្នុងការគណនារបាយការណ៍ហិរញ្ញវត្ថុ និងការពិនិត្យ។

សម័យឆ្លាតវៃ (19th Century) ជាការអភិវឌ្ឍន៍វិជ្ជាជីវនៅក្នុងសម័យនេះសវនកម្មបានក្លាយទៅជាវិជ្ជាជីវៈជាក់លាក់ជាមួយនឹងការបង្កើតកម្មវិធីបណ្តុះបណ្តាលនិងអង្គការសវនកម្មដំបូងៗ។ ដោយនូវសម័យសម័យទំនើប

(20th Century) កំណត់ត្រាសម្រាប់ការត្រួតពិនិត្យការផ្តល់កំណត់ត្រាសម្រាប់ការត្រួតពិនិត្យ បានកើតមានដោយមានការផ្តោតលើការផ្តល់ជូននូវព័ត៌មានហិរញ្ញវត្ថុដែលមានភាពត្រឹមត្រូវ និងក៏ងាយស្រួលក្នុងការស្វែងយល់អំពីរបាយការណ៍ហិរញ្ញវត្ថុទាំងនោះគ្រប់ប្បញ្ញត្តិទាំងអស់។ សម័យសម័យថ្មី( 21st Century) បច្ចេកវិទ្យា និងសវនកម្មឌីជីថលបច្ចេកវិទ្យាបានចូលមកជួយធ្វើឱ្យដំណើរការសវនកម្មមានប្រសិទ្ធភាពជាងមុន។ ជាការប្រើប្រាស់ទិន្នន័យធំ និងការវិភាគទិន្នន័យបានផ្តល់ឱ្យមានភាពជឿជាក់លើការពិនិត្យនិងការវាយតម្លៃ ទៅលើរបាយការណ៍ហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវ [១]។

ដូចនេះហើយប្រវត្តិសាស្ត្រនៃសវនកម្មបានធ្វើឱ្យមានការកែលម្អ និងការកំណត់ត្រាក្នុងការគ្រប់គ្រងហិរញ្ញវត្ថុវាបានក្លាយជាធាតុសំខាន់ក្នុងការបង្កើតទំនុកចិត្ត និងភាពច្បាស់លាស់ក្នុងអង្គភាពហិរញ្ញវត្ថុ។ ប្រវត្តិនៃរបាយការណ៍ហិរញ្ញវត្ថុ (Financial Statements) វាគឺជារឿងដ៏គួរឱ្យចាប់អារម្មណ៍មួយព្រោះថារបាយការណ៍ហិរញ្ញវត្ថុនេះមានប្រវត្តិវែងឆ្ងាយដែលអាចតាមដានតាំងពីសម័យបុរាណកាលមកម្លេះ។ ដោយសម័យបុរាណក្នុងសម័យបុរាណមានការចេញផ្សាយ ទិន្នន័យហិរញ្ញវត្ថុដែលស្របតាមការប្រព្រឹត្តិនិង ការធ្វើជាភាពបញ្ជាក់អំពីការចំណាយនិងចំណូល។ ជា( ឧទាហរណ៍: នាពេលនោះមានអ្នកជំនាញជាច្រើនបានប្រើក្រដាសថ្លៃដើម្បីកត់ត្រាទិន្នន័យក្នុងការធ្វើរបាយការណហិរញ្ញវត្ថុ)។ សម័យមធ្យមការប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុបានកើនឡើងយ៉ាងច្រើននៃការបញ្ជាក់ពីសកម្មភាពហិរញ្ញវត្ថុនិងការចំណាយបានក្លាយជាការសំខាន់សម្រាប់ការគ្រប់គ្រង។ សម័យឧស្សាហ៍កម្មនៅសតវត្សទី១៩ និង ២០ របាយការណ៍ហិរញ្ញវត្ថុបានក្លាយជាឧបករណ៍សំខាន់សម្រាប់ក្រុមហ៊ុនធំៗដើម្បីជានីតិវិធីក្នុងការគ្រប់គ្រងរបាយការណហិរញ្ញវត្ថុ វាគឺត្រូវបានធ្វើឱ្យមានស្តង់ដារដោយអង្គភាពជាតិនានាអនុវត្តដើម្បីធានាថាទិន្នន័យគឺមានភាពត្រឹមត្រូវ នឹងអាចប្រៀបធៀបបានក្នុងការបង្ហាញថារបាយការណ៍ហិរញ្ញវត្ថុត្រូវបានទទួលស្គាល់។ ការបង្កើតស្តង់ដារប្រាក់: ក្នុងឆ្នាំ១៩៤០ និង ១៩៥០ អង្គការដូចជា FASB (Financial Accounting Standards Board) និង IASB (International Accounting Standards Board) គឺបានបង្កើតស្តង់ដារហិរញ្ញវត្ថុដែលវាជួយក្នុងការកំណត់ច្បាប់និងការអនុវត្តសម្រាប់ការបញ្ជាក់ពីរបាយការណ៍ហិរញ្ញវត្ថុស្របតាមអនុលោមភាព។ សម័យបច្ចុប្បន្ន សព្វថ្ងៃនេះគឺប្រព័ន្ធហិរញ្ញវត្ថុមានភាពចម្រុះ និងស្មុគស្មាញជាងមុនដោយមានការប្រើប្រាស់បច្ចេកវិទ្យាថ្មី និងការវាយតម្លៃដោយគ្រប់គ្រងធ្វើឱ្យការផ្តល់នូវរបាយការណ៍ហិរញ្ញវត្ថុមានភាពត្រឹមត្រូវ និងប៉ាន់ស្មានបានកាន់តែប្រសើរឡើង។ សម្រាប់ប្រទេសកម្ពុជាយើងវិញក៏មានប្រព័ន្ធគ្រប់គ្រងស្តង់គណនេយ្យរបាយការណ៍ហិរញ្ញវត្ថុផងដែរគឺCIFRS & CIAS ដែលតម្រូវឱ្យគ្រប់អ្នកកាន់បញ្ជីការគណនេយ្យទាំងអស់ត្រូវអនុវត្តតាមជាកំហិតនិងស្របទៅតាមអនុលោមភាព។

**២.៣.៣. ប្រភេទសវនកម្ម**

ពាក្យថ"សវនកម្ម"គឺទូលំទូលាយណាស់ព្រោះមានប្រភេទផ្សេងៗគ្នាជាច្រើនដែលនីមួយៗមានតួនាទីនិយោជកនិងគោលបំណងខុសៗគ្នា។ គឺពួកគេអាចត្រូវបានគេចាត់ថ្នាក់យ៉ាងទូលំទូលាយដោយផ្អែកលើអ្នកដែលពួកគេធ្វើការឱ្យ និងគោលបំណងនៃសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុបស់ពួកគេ។ ដោយនៅក្នុងនេះខ្ញុំនឹងលើកយកប្រទេសសវនកម្មចំនួនបួន (៤) ប្រភេទមកនិយាយគឺ៖

**១). ប្រភេទសវនកម្មផ្ទៃក្រៅ** សវនករខាងក្រៅគឺជាអ្នកជំនាញឯករាជ្យដែលមិនមែនជាបុគ្គលិករបស់ក្រុមហ៊ុនដែលពួកគេកំពុងធ្វើសវនកម្ម។ គឺពួកគេជាធម្មតាត្រូវបានជួលដោយគណនេយ្យសាធារណៈ ឬក្រុមហ៊ុនសវនកម្ម។ តួនាទីចម្បងរបស់ពួកគេគឺផ្តល់គោលបំណង និងមតិឯករាជ្យលើថាតើរបាយការណ៍ហិរញ្ញវត្ថុ

របស់ក្រុមហ៊ុនត្រូវបានបង្ហាញដោយយុត្តិធម៌និងគោរពតាមស្តង់ដារគណនេយ្យដែលពាក់ព័ន្ធ( ដូចជា GAAP ឬ IFRS) ដែរឬទេ។ គោលបំណងដើម្បីបន្ថែមភាពជឿជាក់លើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់អ្នកប្រើប្រាស់ខាងក្រៅដូចជា វិនិយោគិន ម្ចាស់បំណុល និងនិយតករ។ អ្នកណាដែលពួកគេរាយការណ៍ទៅភាគទុនិក ក្រុមប្រឹក្សាភិបាល ឬគណៈកម្មាធិការសវនកម្មនៃក្រុមហ៊ុនអតិថិជន។វិញ្ញាបនប័ត្រគន្លឹះគណនេយ្យករសាធារណៈដែលមានវិញ្ញាបនប័ត្រ (CPA) គឺជាការរចនាសាមញ្ញបំផុត និងចាំបាច់សម្រាប់សវនករដែលចុះហត្ថលេខាលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសាធារណៈ។

២). **ប្រភេទសវនករផ្ទៃក្នុង** គឺជាបុគ្គលិករបស់ក្រុមហ៊ុនផ្ទាល់ដែលពួកគេធ្វើសវនកម្ម។ ពួកគេធ្វើការនៅក្នុងអង្គការដើម្បីវាយតម្លៃនិងកែលម្អប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យ ការគ្រប់គ្រងផ្ទៃក្នុង និងដំណើរការអភិបាលកិច្ចរបស់ខ្លួន។ វិសាលភាពរបស់ពួកគេគឺ ទូលំទូលាយជាងសវនករខាងក្រៅហើយជារឿយៗគឺពង្រីកលើសពីបញ្ហាហិរញ្ញវត្ថុ ដើម្បីរួមបញ្ចូលប្រសិទ្ធភាពប្រតិបត្តិការ ការអនុលោមតាមគោលនយោបាយផ្ទៃក្នុង និងការគ្រប់គ្រងហានិភ័យ។ គោលបំណងដើម្បីជួយអង្គការសម្រេចបាននូវគោលបំណងរបស់ខ្លួនដោយផ្តល់នូវការយល់ដឹងនិងអនុសាសន៍ដោយផ្អែកលើការវិភាគនិងការវាយតម្លៃនៃទិន្នន័យនិងដំណើរការអាជីវកម្ម ពួកគេដើរតួជាមុខងារឯករាជ្យនៅក្នុងអង្គការ។ ពួកគេរាយការណ៍ទៅអ្នកណា តាមមុខងារ ពួកគេរាយការណ៍ទៅគណៈកម្មាធិការសវនកម្មឬក្រុមប្រឹក្សាភិបាលដើម្បីរក្សាឯករាជ្យភាពរបស់ពួកគេពីការគ្រប់គ្រង។ រដ្ឋបាលពួកគេអាចរាយការណ៍ទៅនាយកប្រតិបត្តិជាន់ខ្ពស់ដូចជា CEO ឬ CFO ។ វិញ្ញាបនបត្រសំខាន់ៗសវនករផ្ទៃក្នុងដែលមានការបញ្ជាក់ (CIA) គឺជាវិញ្ញាបនប័ត្រជាសកលសម្រាប់សវនករផ្ទៃក្នុង។ឧទាហរណ៍៖ ក្រុមសវនកម្មផ្ទៃក្នុងនៅមន្ទីរពេទ្យធំមួយពិនិត្យដំណើរការចេញវិក្កយបត្រអ្នកជំងឺដើម្បីធានាបាននូវភាពត្រឹមត្រូវនិងការអនុលោមតាមបទប្បញ្ញត្តិថែទាំសុខភាព។

៣). **ប្រទេភសវនកម្មរដ្ឋាភិបាល** គឺធ្វើការសម្រាប់ទីភ្នាក់ងារសហព័ន្ធ រដ្ឋ ឬរដ្ឋាភិបាលក្នុងតំបន់។ តួនាទីរបស់ពួកគេគឺដើម្បីធានាថាថវិការបស់រដ្ឋាភិបាលត្រូវបានចំណាយយ៉ាងត្រឹមត្រូវ និងមានប្រសិទ្ធភាព ហើយភ្នាក់ងាររដ្ឋាភិបាលកំពុងអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិ។ គឺពួកគេធ្វើសវនកម្មទាំងភ្នាក់ងាររដ្ឋាភិបាល និងអង្គភាពឯកជនដែលទទួលបានជំនួយពីរដ្ឋាភិបាលឬកិច្ចសន្យា។ គោលបំណងដើម្បីធានានូវគណនេយ្យភាព និងតម្លាភាពក្នុងការប្រើប្រាស់មូលនិធិសាធារណៈនិងប្រតិបត្តិការរបស់អង្គភាពរដ្ឋាភិបាល។

នរណាគេរាយការណ៍ទៅប្រធានទីភ្នាក់ងាររដ្ឋាភិបាលរបស់ពួកគេឬក្នុងករណីស្ថាប័នសវនកម្មកំពូល ( ដូចជាការិយាល័យគណនេយ្យភាពរដ្ឋាភិបាល - GAO - នៅសហរដ្ឋអាមេរិក ) ទៅកាន់ស្ថាប័ននីតិប្បញ្ញត្តិ។ វិញ្ញាបនប័ត្រសំខាន់ៗអ្នកជំនាញសវនកម្មរដ្ឋាភិបាលដែលមានការបញ្ជាក់ (CGAP) គឺជាវិញ្ញាបនប័ត្រទូទៅ។ ដោយសវនកររដ្ឋាភិបាលជាច្រើនក៏កាន់ CPA ឬ CIA ផងដែរ។ ឧទាហរណ៍៖ សវនករមកពីការិយាល័យសវនកម្មជាតិពិនិត្យថវិកា និងចំណាយរបស់ក្រសួងការពារជាតិ។

៤). **ប្រភេទសវនកម្មកោសល្យវិច្ច័យ** គឺជាអ្នកឯកទេសដែលរួមបញ្ចូលគ្នានូវជំនាញគណនេយ្យ សវនកម្មនិងជំនាញស៊ើបអង្កេតដើម្បីពិនិត្យមើលកំណត់ត្រាហិរញ្ញវត្ថុយ៉ាងលម្អិត។ ដោយថាពួកគេត្រូវបានហៅជាញឹកញាប់ឱ្យស៊ើបអង្កេតការក្លែងបន្លំ ការកេងបន្លំ ឬឧក្រិដ្ឋកម្មហិរញ្ញវត្ថុផ្សេងទៀតដែលសង្ស័យ។ ការងាររបស់ពួកគេគឺផ្តោតជាពិសេសឆ្ពោះទៅរកដំណើរការផ្លូវច្បាប់។ គោលបំណង ដើម្បីបង្ហាញនិងចងក្រងជាឯកសារអំពីកំហុសហិរញ្ញវត្ថុគណនាការខូចខាតសេដ្ឋកិច្ច និងបង្ហាញការរកឃើញក្នុងការកំណត់ផ្លូវច្បាប់។ ពួក

គេកំពុងស្វែងរកភស្តុតាងដែលអាចប្រើនៅក្នុងតុលាការ។ ជាធម្មតាពួកគេត្រូវបានជួលដោយមេធាវី ភ្នាក់ងារអនុវត្តច្បាប់សាជីវកម្មឬក្រុមហ៊ុនធានារ៉ាប់រងដើម្បីជួយក្នុងការស៊ើបអង្កេត។ វិញ្ញាបនប័ត្រគន្លឹះអ្នកត្រួតពិនិត្យការក្លែងបន្លំដែលមានការបញ្ជាក់ (CFE) គឺជាស្តង់ដារមាសសម្រាប់វិជ្ជាជីវៈនេះ។ មនុស្សជាច្រើនក៏ជា CPAs ផងដែរ។ ឧទាហរណ៍៖ CFE ដែលជួលដោយក្រុមហ៊ុនមួយដើម្បីស៊ើបអង្កេតការអះអាងរបស់អ្នកបញ្ចេញព័ត៌មានដែលថានាយកប្រតិបត្តិជាន់ខ្ពស់កំពុងប្រើអ្នកលក់ក្លែងក្លាយដើម្បីកេងបន្លំប្រាក់ [10] ។

# ជំពូកទី៣
# នីតិវិធីនៃការធ្វើសវនកម្មរបស់ក្រុមហ៊ុនខេ ភី អឹម ជី ខេមបូឌា លើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

## ៣.១. ស្ថានភាពទូទៅរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក គឺបានទទួអាជ្ញាប័ណ្ណជាធនាគារពាណិជ្ជដែលមានប្រិតបត្តិការ និងចុះបញ្ជីក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារ ត្រូវបានបង្កើតឡើងជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី19 ខែវិច្ឆិកា ឆ្នាំ2003 ក្រោមការចុះបញ្ជីលេខ 1846**E**/2003 ហើយបន្ទាប់មកបានប្តូរលេខចុះបញ្ជីការ 00005269 ចេញដោយក្រសួងពាណិជ្ជកម្ម (MoC) នៅក្រមឈ្មោះដើម វីសិនហ្វាន់ (ខេមបូឌា) អិលធីឌី។ នៅថ្ងៃទី18 ខែឧសភា ឆ្នាំ2004 ធនាគារទទួលបានអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជា (NBC)។ នៅថ្ងៃទី17 ខែកុម្ភៈ ឆ្នាំ2011 ធនាគារទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជាជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDI) ក្នុងការធ្វើអាជីវកម្មសេវកម្ម ទទួលប្រាក់បញ្ញើពីធនាគារជាតិនៃកម្ពុជា។

ធនាគារជាបុត្រសម្ព័ន្ធរបស់ វីសិនហ្វាន់ អន្តរជាតិ ដែលមានកម្មសិទ្ធ 99.9998% ដែលជាក្រុមហ៊ុនចុះបញ្ជីនៅសហរដ្ឋអាមេរិក ។ នៅថ្ងៃទី21 ខែឧសភា ឆ្នាំ2018 ធនាគារជាតិនៃកម្ពុជា បានអនុម័តជាផ្លូវការទៅលើការផ្ទេរភាគហ៊ុន 100% របស់ធនាគារទៅឱ្យ ធនាគារ អ៊ូរី កូរ៉េ ដែលជាធនាគារបានបង្កើតឡើងនៅក្នុងសាធារណៈរដ្ឋកូរ៉េ ហើយបានប្តូរឈ្មោះធនាគារទៅជា ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក។

### ៣.១.១. ប្រវត្តិរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

នៅថ្ងៃទី22 ខែកក្កដា ឆ្នាំ2019 ធនាគារបានចុះកិច្ចព្រមព្រៀងរួមបញ្ចូលគ្នាជាមួយគ្រឹះស្ថាន Woori Finance Cambodia Plc. (WFC) ដែលមានម្ចាស់ភាគហ៊ុនតែមួយគត់ (ធនាគារ អ៊ូរី កូរ៉េ) ប្រតិបត្តិការអាជីវកម្មចម្បងជាសេវាកម្មមីក្រូហិរញ្ញវត្ថុជូនប្រជាជន ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកម្ពុជាក្នុងការលើកស្ទួយដល់ជីវភាពរស់នៅរបស់ប្រជាជននៅតាមសហគមន៍ ដោយផ្តោតទៅលើការបង្កើនប្រាក់ចំណូលគឺតាមរយៈការលើកកម្ពស់សកម្មភាពអាជីវកម្មរបស់អង្គភាពខ្នាតតូច និងមធ្យម រួមការធ្វើអាជីវកម្មនៅតាមជនបទនិងវិស័យកសិកម្មដោយប្រើប្រាស់សេវាប្រាក់កម្ចីនិងប្រាក់បញ្ញើ។ ដោយក្រមកិច្ចសន្យាព្រមព្រៀងគឺជារួមបញ្ចូលគ្នា WFC នឹងត្រូវបានរំលាយបន្ទាប់ពីការរួមបញ្ចូលគ្នារួច។ ការរួមបញ្ចូលគ្នានិងការរំលាយ WFC នេះមានប្រសិទ្ធិភាពនៅថ្ងៃទី10 ខែកុម្ភៈ ឆ្នាំ2020 គឺថាដោយមានការអនុម័តពីធនាគារជាតិនៃកម្ពុជានិងក្រសួងពាណិជ្ជកម្ម។ នៅថ្ងៃទី16 ខែវិច្ឆិកា ឆ្នាំ2021 និងថ្ងៃទី2 ខែធ្នូ ឆ្នាំ2021 ក្រុមហ៊ុនដាប់ប៊ែលយូប៊ីហ្វាន់នែន ឯ.ក បានទទួលការអនុម័តជាផ្លូវការពីធនាគារជាតិនៃកម្ពុជានិងក្រសួងពាណិជ្ជកម្មគឺដើម្បីធ្វើប្រតិបត្តិការអាជីវកម្មក្រោមឈ្មោះ **«ធនាគារ អ៊ូរី (ខេមបូឌា) ម.ក»**។

លើសពីនេះទៀតធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្មក៏បានអនុម័តក្នុងការផ្ទេរហ៊ុនចំនួន ១ ហ៊ុនពីធនាគារ អ៊ូរី កូរ៉េ ទៅឱ្យលោក Hong Ju Kim ដែលជាជនជាតិកូរ៉េ។ ធនាគារបានប្រកាស និងបានចាប់ផ្តើមធ្វើប្រតិបត្តិការជាផ្លូវការក្នុងនាមជាធនាគារពាណិជ្ជសាធារណៈនៅថ្ងៃទី3 ខែមករា ឆ្នាំ 2022។

ដោយផ្លូវការ និងពង្រីសាខាអាជីវកម្មរបស់ខ្លួនទៅតាមតំបន់ផ្សេងៗរបស់ខ្លួនស្របតាមគោលការណ៍របស់ខ្លួន

៣.១.២. ទស្សនវិស័យ ឬបេសកកម្មរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

សកម្មភាពអាជីវកម្មចម្បងរបស់ធនាគារគឺ ការផ្តល់សេវាកម្ម និងផលិតផលហិរញ្ញវត្ថុផ្សេងៗក៏ដូចជាប្រាក់បញ្ញើឥណទាន រួមទាំងសេវាផ្ទេរប្រាក់ក្នុងស្រុកនិងក្រៅប្រទេស សេវាធនាគារចល័ត សេវាទូទាត់សាច់ប្រាក់ សេវាកម្មម៉ាស៊ីនដកនិងដាក់ប្រាក់ដោយស្វ័យប្រវត្តិ ក៏រួមលិខិតធានារបស់ធនាគារនិងសេវាកម្មធនាគារផ្សេងទៀតដែលផ្តល់សេវាជូនប្រជាជនកម្ពុជា តាមរយៈការិយាល័យកណ្តាល និងសាខារបស់ខ្លួននៅក្នុងរាជធានីភ្នំពេញ និងសាខាតាមបណ្តាលខេត្តផ្សេងៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
ការិយាល័យចុះបញ្ជីរបស់ធនាគារមានទីតាំងនៅអគារលេខ 398 មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ធនាគារ អ៊ូរី មានប្រតិបត្តិការចំនួន 25 ខេត្តក្រុង ដែលមានសាខាបណ្តាញចំនួន 140 សាខា (ឆ្នាំ2022 និង 138 សាខា)។

**៣.១.៣. រចនាសម្ព័ន្ធគ្រប់គ្រងរបស់ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក**

ការបែងចែករចនាសម្ព័ន្ធរបស់ធនាគារគឺធ្វើទៅតាមឋានានុក្រមនៃការគ្រប់គ្រងធំៗចំនួនពីរគឺ៖

<u>ក្រុមប្រឹក្សាភិបាល</u>




ដោយយោងតាមរបាយការណ៍ដែលបានដកស្រង់ចេញពីសវនករឯករាជ្យក្នុងការិយបរិច្ឆេទនៃការធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននៅក្នុងពេលឆ្នាំដែលបានធ្វើសវនកម្មប៉ុណ្ណោះដោយបង្ហាដូចថា៖

ក្រុមប្រឹក្សាភិបាលដែលបានបម្រើការងារក្នុងកំឡុងការិយបរិច្ឆេទនិងនៅថ្ងៃដែលចេញរបាយការណ៍នេះរួមមាន៖

| | |
|---|---|
| លោក Sung Wook Jung | ប្រធានក្រុមប្រឹក្សាភិបាល |
| អ្នកនាង Fiona Michelle Whyte | សមាជិក |
| លោក គី ប៊ុនទ្រា | សមាជិក |
| លោក Kwang Hui Ku | សមាជិក |
| លោក Hong Ju Kim | សមាជិក និងអគ្គនាយកប្រតិបត្តិ |

## របនាសម្ព័ន្ធអ្នកគ្រប់គ្រង

សមាជិកអ្នកគ្រប់គ្រងដែលបានបម្រើការងារក្នុងកំឡុងការិយបរិច្ឆេទ និងនៅថ្ងៃដែលចេញរបាយការណ៍នេះរួមមាន៖

| | |
|---|---|
| លោក Hong Ju Kim | អគ្គនាយកប្រតិបត្តិ |
| លោក Dong Woo Shin | អគ្គនាយកហិរញ្ញវត្ថុ |
| លោក សុខ សុថា | អគ្គនាយកប្រតិបត្តិការទី១ |
| លោក ព្រាប ពិសិដ្ឋ | អគ្គនាយកប្រតិបត្តិការទី២ |
| លោក Hyoseok Lee | អគ្គនាយកគាំទ្រប្រតិបត្តិការ |
| លោក ហ៊ុន សុភ័ក្រ្ត | អគ្គនាយកឥណទាន |
| លោក វ៉ា លួងសុរិន | អគ្គនាយកព័ត៌មានវិទ្យា |
| លោកស្រី តុប សុក្រសម្ភារ | អគ្គនាយិកាគ្រប់គ្រងហានិភ័យ |
| កញ្ញា ហ៊ិន សុជាត់ | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| លោកស្រី ស៊ីវ ច័ន្ទវលក្ខណ៍ | មន្ត្រីប្រតិបត្តិតាម |

ដោយអ្នកគ្រប់គ្រងទាំងអស់មានតួនាទី គ្រប់គ្រងទៅតាមឋានានុក្រមនៃឧបសម្ព័ន្ធដែលបានចែងទៅតាមមុខងាររៀងៗខ្លួនអ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗដែលទទួលបានត្រឹមការិយបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ។

## ភាគកម្មរបស់ក្រុមប្រឹក្សាភិបាល

ព័ត៌មានស្តីពីការកាន់កាប់ភាគហ៊ុនរបស់ធនាគារ និងក្រុមប្រឹក្សាភិបាលរបស់ខ្លួនគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ 2023 មានដូចខាងក្រោម៖

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023<br>*(%)ភាគរយនៃម្ចាស់កម្មសិទ្ធ* | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022<br>*(%)ភាគរយនៃម្ចាស់កម្មសិទ្ធ* |
|---|---|---|
| លោក Hong Ju Kim | 0.00001% | 0.00001% |

ក្រៅពីការបង្ហាញខាងលើនេះ ពុំមានអភិបាលផ្សេងណាដែលកាន់កាប់ភាគហ៊ុននៅក្នុងធនាគារ ឬនៅក្រុមហ៊ុនដែលពាក់ព័ន្ធណាមួយផ្សេងទៀតឡើយសម្រាប់អ្នកគ្រប់គ្រងដែលជាសមាជិកក្រុមប្រឹក្សាភិបាល។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងកំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះគឺ មិនមានកិច្ចព្រមព្រៀងណាមួយដែលធនាគារជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះបានផ្តល់នូវលទ្ធភាពដល់សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ឱ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬជាប័ណ្ណបំណុលរបស់ធនាគារ ឬសាជីវកម្មដទៃទៀតនោះឡើយ។

នៅក្នុងកំឡុងការិយបរិច្ឆេទរាយការណ៍នេះ គឺពុំមានអភិបាលណាម្នាក់របស់ធនាគារបានទទួល ឬមានសិទ្ធទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបាន រួមបញ្ចូលនៅក្នុងបរិលាភសរុបទទួលបាន ឬដល់កាលកំណត់ដែលត្រូវទទួលបានដោយក្រុមប្រឹក្សាភិបាល ដូចដែលនិងបានបង្ហាញទាំងស្រុងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាបានធ្វើឡើងដោយធនាគារ ឬដោយក្រុមហ៊ុនពាក់ព័ន្ធជាមួយនឹងធនាគារ ដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិករបស់សាជីវកម្ម ឬក៏ជាមួយក្រុមហ៊ុនដែលមានអភិបាលជាសមាជិកដែលមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ច្រើននោះទេលើកលែងតែការដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុប៉ុណ្ណោះ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានភារៈធ្វើការអះអាងបញ្ជាក់ថារាល់ របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយការរៀបចំឡើងយ៉ាងត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ 2023 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ ដោយនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចំបាច់ត្រូវ៖

(i) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្របនានា ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព។

(ii) អនុលោមទៅតាមស្តង់ដាររបាយការណ៍ការ ទាក់ទងទៅនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ស.រ.ទ.ហ.អ.ក) ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះ ដើម្បីបង្ហាញពីការពិត និងត្រឹមត្រូវ គឺត្រូវតែបង្ហាញពន្យល់ និងកំណត់បរិមាណឱ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

(iii) ត្រួតពិនិត្យប្រព័ន្ធដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារនិងរក្សាទុកនៅបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព។

(iv) វាយតម្លៃនូវលទ្ធភាពរបស់ធនាគារ ក្នុងការបន្តនិរន្តរ៍ភាពអាជីវកម្ម និងទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយណាដែល ទាក់ទងទៅនឹងនិរន្តរ៍ភាពនៃការធ្វើអាជីវកម្មនិងប្រើប្រាស់មូលដ្ឋាននិរន្តរ៍ភាព នៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការធនាគារ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ និង

(v) ត្រួតពិនិត្យ និងដឹកនាំធនាគារឱ្យមានប្រសិទ្ធភាព លើរាល់សេចក្តីសម្រេចដែលមានសារៈសំខាន់ទាំងអស់ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ធនាគារហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា បានអនុវត្តនូវរាល់តម្រូវការដូចដែលបានរាយការណ៍ខាងលើកនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ទៅតាមនីតិវិធី និងគោលនយោបាយណ៍របស់ប្រព័ន្ធធនាគារ។

## ៣.២. វិធីសាស្រ្ត និងនីតិវិធីរបស់សវនករផ្ទៃក្រៅទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

ធ្វើការកំណត់និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុគឺដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុលត្រូវលើការតាក់តែង និងអនុវត្តនូវនិតិវិធីសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះនិងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់និងសមស្របគឺសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្ម ដោយវិធីសាស្រ្តដូចខាងក្រោមៈ

- ធ្វើការស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មក្នុងគោលបំណងដើម្បីតាក់តែងនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារឡើយ។
- ធ្វើការវាយតម្លៃលើភាពសមស្រប លើគោលនយោបាយណ៍គណនេយ្យ ដែលធនាគារបានអនុវត្ត និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធនានាដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រងក្នុងការអនុវត្តតាមនីតិវិធីគោលនយោបាយណ៍។
- ធ្វើការវាយតម្លៃលើការបង្ហាញទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដោយរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាននិងវាយតម្លៃថា តើរបាយការណ៍ហិរញ្ញវត្ថុគឺត្រូវបានបង្ហាញពីប្រតិបត្តិការនិងជាព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវមួយក៏ស្របទៅតាមប្រព័ន្ធស្តង់ដារគណនេយ្យជាតិ និងគណនេយ្យអន្តរជាតិ។
- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរ៍ភាពនៃគណនេយ្យហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រងដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាននិងធ្វើការសន្និដ្ឋានថា តើភាពមិនប្រាកដប្រជាជាសារវន្តបានកើតឡើងពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ឬជាលក្ខខណ្ឌដែលអាចបង្កឱ្យមានមន្ទិលជាសារវន្តលើលទ្ធផលរបស់ធនាគារដើម្បីបន្តនិរន្តរ៍ភាពអាជីវកម្មដែរ ឬទេ?។

បានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុលើរបាយការណ៍ប្រាក់ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ។ របាយការណ៍ស្តីពីការបម្រែលបម្រួលមូលធន និងប្រព័ន្ធរបាយការណ៍លំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទ ដែលបានបញ្ចប់ និងកំណត់សម្គាល់ ដែលរួមមានគោលនយោបាយនេយ្យសារវន្ត ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗ ដែលនឹងត្រូវបង្ហាញ។

របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ បានង្ហាញនូវភាពត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ធនាគារសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងទៅនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា( ស.រ.ទ.ហ.អ.ក )។បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មជាតិនៃកម្ពុជាដែលត្រូវបានធានាអះអាងពី KPMG ថាស្របទៅតាមស្តង់ដាហើយមានភាពឯករាជ្យពីធនាគារដោយស្របទៅតាមលក្ខខណ្ឌតម្រូវនៃក្រមសីលធម៌វិជ្ជាជីវៈនៃសវនករផងដែរ។ ចំណែកឯភស្តុតាងសវនកម្មដែលប្រមូលបានគឺមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មជា

សារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ។ និតិវិធីនិងវិធីសាស្ត្រទាំងអស់ដែលបានអនុវត្តគឺយោងទៅតាមស្តង់ដារនៃគណនេយជាតិនិងអន្តរជាតិគឺ FASB (Financial Accounting Standards Board) និង IASB (International Accounting Standards Board).

**៣.២.១. វិធីសាស្ត្រនៃការធ្វើសវនកម្មរបស់ក្រុមហ៊ុនខេ ភី អឹម ជី ខេមបូឌា**

វិធីសាស្ត្ររបស់ក្រុមហ៊ុនសវនកម្មឯករាជ្យ KPMG Cambodiaគឺជាដំណើរការជាប្រព័ន្ធដែលប្រើដើម្បីពិនិត្យដោយឯករាជ្យនូវរបាយការណ៍ហិរញ្ញវត្ថុនិងការត្រួតពិនិត្យផ្ទៃក្នុងរបស់ស្ថាប័ន។ ដោយគោលដៅចម្បងគឺដើម្បីផ្តល់នូវមតិមិនលំអៀងទៅលើ ថាតើរបាយការណ៍ហិរញ្ញវត្ថុបង្ហាញពីទិដ្ឋភាពពិតនិងយុត្តិធម៌នៃប្រតិបត្តិការនិងទីតាំងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ ដោយដំណើរការនេះជួយធានាបាននូវភាពត្រឹមត្រូវ តម្លាភាព និងការអនុលោមតាមស្តង់ដារគណនេយ្យ។ វិធីសាស្ត្រធម្មតានៃសវនករួមមានដំណាក់កាលសំខាន់ៗដូចខាងក្រោមៈ

- ការធ្វើផែនការនិងការរៀបចំ៖ ដំណាក់កាលដំបូងនេះពាក់ព័ន្ធនឹងការយល់ដឹងអំពីអាជីវកម្ម ឧស្សាហកម្មនិងបរិយាកាសបទប្បញ្ញត្តិរបស់អតិថិជន។ វាយតម្លៃហានិភ័យ កំណត់វិសាលភាពនៃសវនកម្ម និងបង្កើតផែនការសវនកម្មលម្អិត គឺវាមានសារៈសំខាន់សម្រាប់សវនកម្មប្រកបដោយប្រសិទ្ធភាព។
- ការវាយតម្លៃហានិភ័យនិងការធ្វើតេស្តត្រួតពិនិត្យផ្ទៃក្នុង៖ វាយតម្លៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនដើម្បីកំណត់ភាពទន់ខ្សោយដែលអាចនាំឱ្យមានការខុសឆ្គងជាសារវន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ នេះពាក់ព័ន្ធនឹងការសាកល្បងប្រសិទ្ធភាពនៃការគ្រប់គ្រងទាំងនេះ។ នីតិវិធីសំខាន់ៗនេះគឺជាស្នូលនៃសវនកម្មដែលសវនករធ្វើតេស្តលម្អិតអំពីប្រតិបត្តិការហិរញ្ញវត្ថុ និងសមតុល្យ។
- នីតិវិធីវិភាគ៖ ការវិភាគទិន្នន័យហិរញ្ញវត្ថុដើម្បីកំណត់និន្នាការមិនធម្មតា ឬការប្រែប្រួល។
- ការធ្វើតេស្តព័ត៌មានលម្អិត៖ ពិនិត្យមើលប្រតិបត្តិការនិងសមតុល្យបុគ្គលដើម្បីផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនិងសុពលភាពរបស់ពួកគេ នេះអាចរួមបញ្ចូលគំរូ និងបច្ចេកទេសផ្សេងទៀត។
- ការវិភាគ និងសេចក្តីសន្និដ្ឋាន៖ សវនករប្រមូល និងវាយតម្លៃភស្តុតាងទាំងអស់ដែលប្រមូលបានក្នុងអំឡុងពេលសវនកម្ម។ ហើយដោយផ្អែកលើភស្តុតាងនេះ ពួកគេនឹងបង្កើតជាមតិលើរបាយការណ៍ហិរញ្ញវត្ថុ។ ការរាយការណ៍ និងការទំនាក់ទំនង៖ ដំណាក់កាលចុងក្រោយពាក់ព័ន្ធនឹងការរៀបចំរបាយការណ៍សវនកម្មដែលបង្ហាញពីការរកឃើញ និងមតិរបស់សវនករ។ របាយការណ៍នេះត្រូវបានទាក់ទងទៅអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀត។

ដោយបន្ទាប់ពីបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគាររួចរាល់ហើយ គឺក្រុមហ៊ុនសវនកម្មឯករាជ្យ (KPMG) នឹងធ្វើការចេញជារបាយការណ៍វាយតម្លៃវាស់វែងស្តង់ដារទៅតាមមតិ៤យ៉ាងគឺ៖

១).ការយល់ឃើញដែលមិនមានលក្ខណៈគ្រប់គ្រាន់ (Unqualified Opinion)

២).យោបល់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (Qualified Opinion)

៣).មតិអវិជ្ជមាន (Adverse Opinion)

៤).ការបដិសេធការយល់ឃើញ (Disclaimer of Opinion)

**៣.២.២. និតិវិធីនៃការធ្វើសវនកម្មរបស់ក្រុមហ៊ុនខេ ភី អឹម ជី ខេមបូឌា**

នីតិវិធីរបស់ក្រុមហ៊ុន KPMG គឺជាប្រព័ន្ធនៃជំហានបង្គំជាស៊េរី និងបច្ចេកទេសដែលត្រូវបានប្រើដើម្បីបង្កើតជាមតិឯករាជ្យលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។ នីតិវិធីទាំងនេះត្រូវបានរៀបចំឡើងដើម្បីផ្តល់នូវការធានាសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុមិនមានការបញ្ជាក់ខុសជាសារវន្ត ទោះបីជាដោយសារតែ

ការក្លែងបន្លំឬកំហុសក៏ដោយ។ ដំណើរការស្ទួលរបស់សវនករខាងក្រៅអាចបែងចែកជាដំណាក់កាលសំខាន់ៗដូចខាងក្រោម៖

- ការធ្វើផែនការ និងការវាយតម្លៃហានិភ័យ ដាដំណាក់កាលដំបូងនេះគឺមានសារៈសំខាន់សម្រាប់សវនកម្មប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធភាព។ នីតិវិធីរួមមានការទទួលយកនិងបន្តទំនាក់ទំនងអតិថិជនដំបូង សវនករត្រូវតែសម្រេចចិត្តថាតើត្រូវទទួលយកអតិថិជនថ្មី ឬបន្តជាមួយអតិថិជនដែលមានស្រាប់។
- ការវាយតំលៃហានិភ័យនៃសម្ភារៈមិនពិត និងការធ្វើតេស្តការត្រួតពិនិត្យផ្ទៃក្នុង កំណត់អត្តសញ្ញាណ និងវាយតម្លៃហានិភ័យ ដែលអាចនាំឱ្យមានការខុសឆ្គងជាសារវន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ការកំណត់ហានិភ័យពីកំណើតសវនករកំណត់ហានិភ័យដែលទាក់ទងនឹងលក្ខណៈនៃអាជីវកម្មនិងប្រតិបត្តិការរបស់ខ្លួនមុនពេលពិចារណាលើការគ្រប់គ្រងដែលពាក់ព័ន្ធ។
- ការវាយតម្លៃការត្រួតពិនិត្យផ្ទៃក្នុងសវនករវាយតម្លៃការរចនានិងការអនុវត្តប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់អតិថិជនលើរបាយការណ៍ហិរញ្ញវត្ថុ។ នេះរួមបញ្ចូលទាំងការយល់ដឹងអំពីបរិយាកាសត្រួតពិនិត្យ,ដំណើរការវាយតម្លៃហានិភ័យ,សកម្មភាពត្រួតពិនិត្យព័ត៌មាន ទំនាក់ទំនង និងការត្រួតពិនិត្យការត្រួតពិនិត្យ។ ការធ្វើដែរតេស្តប្រសិទ្ធភាពប្រតិបត្តិការនៃការត្រួតពិនិត្យ ប្រសិនបើសវនករមានគម្រោងពឹងផ្អែកលើ ការត្រួតពិនិត្យផ្ទៃក្នុងរបស់អតិថិជន ពួកគេនឹងធ្វើតេស្តដើម្បីទទួលបានភស្តុតាង ដែលបង្ហាញថាការគ្រប់គ្រងកំពុងដំណើរការប្រកបដោយប្រសិទ្ធភាពពេញមួយអំឡុងពេលដែលត្រូវបានធ្វើសវនកម្ម។ ភាពពេញលេញរាល់ប្រតិបត្តិការនិងគណនីដែលគួរបង្ហាញត្រូវបានរួមបញ្ចូល។

## ការវិនិច្ឆ័យ និងការប៉ាន់ស្មាន

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះអ្នកគ្រប់គ្រងគឺបានធ្វើការវិនិច្ឆ័យប៉ាន់ស្មាន និងសន្មតថាដែលមានផលប៉ះពាល់ដល់ការអនុវត្តនូវគោលការណ៍នយោបាយគណនេយ្យរបស់ធនាគារនិងចំនួននៃទ្រព្យសកម្មបំណុល ចំណូលនិងចំណាយដែលបានរាយការណ៍។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនោះ។ការប៉ាន់ស្មាននិងការសន្មតដែលពាក់ព័ន្ធត្រូវបានត្រួតពិនិត្យជាប្រចាំដូចជាការកែប្រែលើការប៉ាន់ស្មានត្រូវបានទទួលស្គាល់តាមវិធីសាស្រ្តទស្សនៈវិស័យ។

### *i. ការវិនិច្ឆ័យ*

ព័ត៌មានអំពីការវិនិច្ឆ័យ ដែលបានធ្វើឡើងក្នុងការអនុវត្តគោលនយោបាយគណនេយ្យដែលមានផលប៉ះពាល់ជាសារវន្ត លើចំនួនទឹកប្រាក់ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់នៃរបាយការណ៍សវនករឯករាជ្យដែលបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុនៃការិយបរិច្ឆេទឆ្នាំដែលបានរងនូវសវនកម្មប៉ុណ្ណោះដែលទាំនៅគឺត្រូវបានកំណត់ថ្នាក់ដូចខាងក្រោម៖

- ការចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ៖ ការវាយតម្លៃគំរូអាជីវកម្ម ដែលទ្រព្យទាំងនោះត្រូវបានកាន់កាប់ និងការវាយតម្លៃថាតើលក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាការទូទាត់តែប្រាក់ដើម និងជាការប្រាក់លើចំនួនប្រាក់ដើមដែលនៅសល់។
- ការបង្កើនលក្ខណៈវិនិច្ឆ័យ៖ គឺសម្រាប់កំណត់ថាតើហានិភ័យឥណទានលើទ្រព្យសកម្មហិរញ្ញវត្ថុបានកើតឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់ដំបូង ដោយកំណត់ទៅលើវិធីសាស្រ្តសម្រាប់បញ្ចូល

ព័ត៌មានក្នុងការវាស់វែងលើការរំពឹងទុក លើការខាតបង់ឥណទាន និងការជ្រើសរើស និងការអនុម័ត លើគំរូដែលប្រើដើម្បីវាស់វែងលើការរំពឹងទុកលើការខាតបង់នៃឥណទាន។

*ii. ការសន្មត់ និងការប៉ាន់ស្មានភាពមិនប្រាកដប្រជា*

ព័ត៌មានអំពីភាពមិនប្រាកដប្រជានៃការសន្មតនិងការប៉ាន់ស្មានដែលមានហានិភ័យជាសារវន្តដែលអាចធ្វើឱ្យមាននិយ័តភាពលើតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនាពេលបន្ទាប់គឺត្រូវបានបញ្ចូលទៅក្នុងកំណត់សម្គាល់ ដូចខាងក្រោមៈ

- កំណត់សម្គាល់ឌីនភាពនៃតម្លៃលើឧបករណ៍ហិរញ្ញវត្ថុៈ ការកំណត់បញ្ចូលសមាសធាតុទៅក្នុងគំរូនៃការវាស់វែងលើការរំពឹកទុកលើការខាតបង់ឥណទាន រួមទាំងការសន្មត់សំខាន់ៗដែលប្រើក្នុងការប៉ាន់ស្មានលំហូរទឹកប្រាក់ ដែលអាចប្រមូលមកវិញ និងការបញ្ចូលព័ត៌មាននៃការប្រមើលនាពេលអនាគត់។
- កំណត់សម្គាល់គឺជាៈ ការកំណត់តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុដែលមិនមានទិន្នន័យ ឬដែលអាចអង្កេតបានជាសារវន្ត។

## ៣.៣. ផលប្រយោជន៍សវនកម្មរបាយការណ៍ហិរញ្ញវត្ថុធនាគារ អ៊ូរី (ខេមបូឌា) ម.ក

ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុបង្ហាញពីព័ត៌មានស្ដីអំពីហានិភ័យនិមួយៗដែលមានគោល ដៅគោលការណ៍ណែនាំនិងវិធានការរបស់ធនាគារដើម្បីវាស់វែង និងគ្រប់គ្រងនូវហានិភ័យដែលកើតឡើងនិងជាការគ្រប់គ្រងនូវដើមទុនរបស់ប្រព័ន្ធធនាគារឱ្យបានល្អប្រសើរជានិរន្តរ៍ផងដែរ។

រាល់របាយការណ៍ដែលត្រូវធ្វើ សវនកម្មមានដូចជាៈ

- ហានិភ័យឥណទាន
- ហានិភ័យទីផ្សារ
- ហានិភ័យសាច់ប្រាក់ងាយស្រួល និង
- ហានិភ័យប្រតិបត្តិការ

ក្រុមប្រឹក្សាភិបាលរបស់ធនាគារមានទំនួលខុសត្រូវរួមសម្រាប់ការបង្កើត និងត្រួតពិនិត្យក្របខ័ណ្ឌ គ្រប់គ្រងហានិភ័យរបស់ធនាគារ។ ក្រុមប្រឹក្សាភិបាលបានបង្កើតគណៈកម្មាធិការគ្រប់គ្រងហានិភ័យ (RMC) ដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យគោលនយោបាយគ្រប់គ្រងហានិភ័យរបស់ធនាគារ និងធានានូវការអនុវត្តន៍សមស្របនៃក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ រួមទាំងការអនុលោមតាមបទប្បញ្ញត្តិ។

គោលនយោបាយគ្រប់គ្រងហានិភ័យរបស់ធនាគារត្រូវបានបង្កើតឡើងដើម្បីកំណត់លក្ខណៈនិងវិភាគហានិភ័យដែលធនាគារបានប្រឈមដើម្បីកំណត់និងគ្រប់គ្រងកម្រិតហានិភ័យឱ្យបានសមស្របនិងតាមដានហានិភ័យ និងការប្រកាន់ភ្ជាប់នូវដែនកំណត់។ គោលនយោបាយ និងប្រព័ន្ធគ្រប់គ្រងហានិភ័យ ត្រូវបានពិនិត្យឡើងវិញជាប្រចាំដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្ដូរលក្ខខណ្ឌទីផ្សារ និងសកម្មភាពរបស់ធនាគារ តាមរយៈស្តង់ដារនៃការបណ្ដុះបណ្ដាល ការគ្រប់គ្រង និងនីតិវិធីគ្រប់គ្រងរបស់ខ្លួន មានគោលបំណងបង្កើតនូវវិន័យ និងការត្រួតពិនិត្យស្ថានភាព ដែលបុគ្គលិកទាំងអស់យល់ពីតួនាទី និងកាតព្វកិច្ចរបស់ពួកគេ។

គណៈកម្មការសវនកម្មរបស់ធនាគារ ត្រួតពិនិត្យពីរបៀបអ្នកគ្រប់គ្រង ដោយអនុលោមតាមគោលការណ៍ និងនីតិវិធីគ្រប់គ្រងហានិភ័យរបស់ធនាគារ និងពិនិត្យឡើងវិញនូវភាពគ្រប់គ្រាន់ នៃក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ

ទាក់ទងនឹងហានិភ័យដែលធនាគារបានប្រឈមមុខ។ គណៈកម្មការសវនកម្មរបស់ធនាគារ ដើរតួនាទីក្នុងការជួយត្រួតពិនិត្យសវនកម្មផ្ទៃក្នុងរបស់ខ្លួន។ សវនកម្មផ្ទៃក្នុងអនុវត្តទាំងការត្រួតពិនិត្យជាប្រចាំ និងជាលក្ខណៈពិសេសនៃការគ្រប់គ្រងហានិភ័យ និងនីតិវិធីដែលលទ្ធផលត្រូវបានរាយការណ៍ជូនទៅគណៈកម្មការសវនកម្មរបស់ធនាគារ និងគណៈគ្រប់គ្រងរបស់ធនាគារក្នុងការតាមដាន។

**៣.៣.១. ផលប្រយោជន៍នៃការធ្វើសវនកម្មរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក**

គឺការផ្តល់ឱ្យព័ត៌មានច្បាស់លាស់ផ្នែកហិរញ្ញវត្ថុរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ប្រសិនបើអតិថិជនឬភាគីម្ខាងទៀតមិនមានលទ្ធភាពបំពេញកាតព្វកិច្ចទៅតាមកិច្ចសន្យាហើយហានិភ័យជាចម្បងនេះគឺកើតចេញតាមរយៈការផ្តល់ឥណទាន និងបុរេប្រទានដល់អតិថិជនធនាគារនានានិងការវិនិយោគលើមូលបត្របំណុលផ្សេងទៀតសម្រាប់គោលបំណងរាយការណ៍អំពីហានិភ័យ គឺធ្វើការពិចារណនិងដាក់រួមបញ្ចូលនូវធាតុទាំងអស់នៃហានិភ័យឥណទានដែលប្រឈម។ គ. ហានិភ័យតាមកាតព្វកិច្ចរបស់បុគ្គលម្នាក់ៗហានិភ័យតាមវិស័យ និងប្រទេស។ ហានិភ័យឥណទានគឺ៖ ជាហានិភ័យខាតបង់ចំណូល និងការខាតបង់ប្រាក់ដើម វាបានកើតឡើងពីឥណទាន និងបុរេប្រទាន និងកិច្ចសន្យាកម្ចីដោយសារអ្នកខ្ចី ឬសមភាគីខកខានមិនទូទាត់សងនៃបំណុល។

*ការគ្រប់គ្រងហានិភ័យឥណទាន*

គណៈកម្មាធិការឥណទានរបស់ធនាគារ រួមជាមួយនឹងការវិភាគ និងការអនុម័តឥណទាន គោលនយោបាយប្រាក់កម្ចី ការស្តារប្រាក់កម្ចី ការត្រួតពិនិត្យប្រាក់កម្ចី ការអភិវឌ្ឍន៍អាជីវកម្ម ការគ្រប់គ្រងហានិភ័យនិងនាយកដ្ឋានហិរញ្ញវត្ថុ និងគណនេយ្យទទួលខុសត្រូវក្នុងការគ្រប់គ្រងហានិភ័យឥណទានរបស់ធនាគារជាយុទ្ធិសាស្រ្ត គណៈកម្មាធិការបានរៀបចំនូវផែនការណ៍ស្នូល ដើម្បីជាការគ្រប់គ្រងហានិភ័យឥណទានហិរញ្ញវត្ថុ ឱ្យស្របទៅតាមគោលដៅ និងគោលនយោបាយរបស់ប្រព័ន្ធគ្រប់គ្រងធនាគារ ដែលបានកំណត់ជានីតិវិធីក្នុងការអនុវត្តកន្លងមក និងទៅតាមគោលការណ៍មួយចំនួនផ្សេងទៀតដូចខាងក្រោម៖

- ធនាគារមានការអនុវត្តហានិភ័យឥណទានសមស្រប និងរួមទាំងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាពដើម្បីកំណត់ឱ្យបានជាប់លាប់នូវ ប្រាក់ឧបត្ថម្ភគ្រប់គ្រាន់ ស្របទៅតាមគោលនយោបាយ និងនីតិវិធីដែលបានបញ្ជាក់របស់ធនាគារ និងការណែនាំអំពីការត្រួតពិនិត្យពាក់ព័ន្ធរបាយការណ៍។
- ការកំណត់អត្តសញ្ញាណវាយតម្លៃ និងការវាស់វែងហានិភ័យឥណទាននៅទូទាំងធនាគារ ពីឧបករណ៍ចាប់ពីបុគ្គលរហូតដល់កម្រិតផលប័ត្រដើម្បីមានភាពងាយស្រួលក្នុងការប្រមូលភស្តុតាងឬទិន្នន័យ។
- ការបង្កើតគោលនយោបាយឥណទានដើម្បីការពារធនាគារប្រឆាំងនឹងហានិភ័យដែលបានកំណត់រួមទាំងតម្រូវការដើម្បីទទួលបានវត្ថុបញ្ចាំពីអ្នកខ្ចីដើម្បីធ្វើការវាយតម្លៃឥណទានដែលកំពុងដំណើរការដ៏រឹងមាំរបស់អ្នកខ្ចី និងដើម្បីតាមដានការប្រឈមមុខនឹងកម្រិតហានិភ័យផ្ទៃក្នុងរបស់ធនាគារផងដែរ។
- ការកំណត់ការប្រមូលផ្តុំនៃការប៉ះពាល់ដោយប្រភេទនៃទ្រព្យសកម្មសមភាគី ឧស្សាហ៍កម្ម កាចំណាត់ថ្នាក់ឥណទាន ទីតាំងភូមិសាស្រ្តគឺជាកត្តាចម្បងក្នុងការកំណត់សម្គាល់ហានិភ័យផងដែរ។
- ការបង្កើតក្របខណ្ឌការត្រួតពិនិត្យដ៏រឹងមាំមួយទាក់ទងនឹងរចនាសម្ព័ន្ធនៃការអនុញ្ញាតសម្រាប់ការធ្វើអនុម័ត និងការបន្តឡើងវិញនូវកន្លែងផ្តល់ឥណទានក៏ត្រូវបានកំណត់ជាក់លាក់ក្នុងរបាយការណ៍។

- ការបង្កើតនិងរក្សាចំណាត់ថ្នាក់ហានិភ័យរបស់ធនាគារដើម្បីចាត់ថ្នាក់ ជាការប៉ះពាល់ដោយយោងទៅតាមកម្រិតនៃហានិភ័យនៃការខកខានចំណាត់ថ្នាក់ហានិភ័យគឺស្ថិតនៅក្រោមការត្រួតពិនិត្យជាប្រចាំ
- បង្កើតនិងថែរក្សាដំណើរការរបស់ធនាគារសម្រាប់ការវាស់វែង ECL រួមទាំងការត្រួតពិនិត្យហានិភ័យឥណទាន ការដាក់បញ្ចូលព័ត៌មានដែលមើលទៅអនាគត និងវិធីសាស្ត្រដែលប្រើដើម្បីវាស់ ECL។
- ធានាថាធនាគារមានគោលនយោបាយ និងនីតិវិធីក្នុងការរក្សាបានត្រឹមត្រូវនិងធ្វើឱ្យមានសុពលភាព
- ការបង្កើតដំណើរការវាយតម្លៃគណនេយ្យហានិភ័យឥណទាន និងដំណើរការវាស់វែងដែលផ្តល់ឱ្យវានូវមូលដ្ឋានរឹងមាំសម្រាប់ប្រព័ន្ធទូទៅ ឧបករណ៍ និងទិន្នន័យដើម្បីវាយតម្លៃហានិភ័យឥណទាន និងគណនីសម្រាប់ECL។ ជាការផ្តល់ដំបូន្មានការណែនាំនិងជំនាញឯកទេសដល់អង្គភាពអាជីវកម្មដើម្បីលើកកម្ពស់ ការអនុវត្តល្អបំផុតនៅទូទាំងធនាគារក្នុងការគ្រប់គ្រងហានិភ័យឥណទាន។

***ការបញ្ចូលព័ត៌មានរំពឹងទុកនៅពេលអនាគត់***

ការរំពឹងទៅលើការវិភាគធនាគារនៅថ្ងៃអនាគត់ ដោយប្រើប្រាស់គំរូតំរែតំរង់ស្ថិតិសម្រាប់ជាការវាយតម្លៃដើម្បីកំណត់ថាតើហានិភ័យឥណទាននៃឧបករណ៍មួយបានកើនឡើងយ៉ាងខ្លាំងចំពោះការវាស់វែងរបស់ ECL ដែរឬទេ?។ ធនាគារបង្កើតសេណារីយ៉ូសេដ្ឋកិច្ចចំនួនបី៖ សេណារីយ៉ូជាមូលដ្ឋាន ករណីអាក្រក់ និងករណីល្អ។ ព័ត៌មានខាងក្រៅដែលត្រូវបានពិចារណារួមមាន ទិន្នន័យសេដ្ឋកិច្ច និងការព្យាករណ៍ដែលចេញផ្សាយដោយស្ថាប័នរបស់រដ្ឋាភិបាល និងអាជ្ញាធររូបិយវត្ថុក្នុងប្រទេសដែលធនាគារបានដំណើរការ អង្គការជាន់ខ្ពស់ដូចជា (Economic Intel-ligent Unit) អង្គភាពជំនាញសេដ្ឋកិច្ច។

ធនាគារបានកំណត់អត្តសញ្ញាណ និងចងក្រងឯកសារអំពីកត្តាជំរុញសំខាន់ៗនៃហានិភ័យឥណទាន និងការខាតបង់ឥណទានសម្រាប់ផលប័ត្រឧបករណ៍ហិរញ្ញវត្ថុនីមួយៗ ដោយការប្រើការវិភាគទិន្នន័យទៅតាមប្រវត្តិសាស្ត្រមានការប៉ាន់ប្រមាទំនាក់ទំនងរវាងអថេរម៉ាក្រូសេដ្ឋកិច្ច និងហានិភ័យឥណទាន និងការបាត់បង់នៃឥណទានមុខងារសេវនកម្មផ្ទៃក្នុងអនុវត្តសវនកម្មទៀងទាត់ធ្វើឱ្យប្រាកដថាការត្រួតពិនិត្យ និងនីតិវិធីដែលត្រូវបានបង្កើតឡើងត្រូវបានរៀបចំ និងអនុវត្តបានគ្រប់គ្រាន់ទៅតាមបទប្បញ្ញត្តិកំណត់។

***ការកើនឡើងយ៉ាងខ្លាំងនូវហានិភ័យឥណទាន***

ធនាគារតាមដានរាល់ទ្រព្យសកម្មហិរញ្ញវត្ថុដែលស្ថិតក្រោមលក្ខខណ្ឌតម្រូវនៃការចុះខ្សោយ ដើម្បីវាយតម្លៃថាតើមានការកើនឡើងគួរឱ្យកត់សម្គាល់នៃហានិភ័យឥណទានចាប់តាំងពីការទទួលស្គាល់ដំបូង។ គឺប្រសិនបើមានការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទាន ធនាគារនឹងវាស់វែងប្រាក់ឧបត្ថម្ភការខាតបង់ដោយផ្អែកទៅលើអាយុកាលជាជាង ECL រយៈពេល 12ខែ។

ធនាគារប្រើចំនួនថ្ងៃដែលហួសកំណត់ជាធាតុចូលចម្បងក្នុងការកំណត់រចនាសម្ព័ន្ធពាក្យរបស់ PD សម្រាប់ការបង្ហាញ។ ធនាគារប្រមូលព័ត៌មានអំពីការអនុវត្ត និងលំនាំដើមអំពីការប្រឈមមុខនឹងហានិភ័យឥណទានដែល ត្រូវបានវិភាគដោយវិស័យអាជីវកម្មរបស់អ្នកខ្ចីរបស់ខ្លួន។

***ការវាស់វែង*** ECL

- ធាតុចូលសំខាន់ៗដែលប្រើសម្រាប់វាស់ ECL គឺ៖
- ប្រូបាប៊ីលីតេនៃលំនាំដើម (PD');
- ការបាត់បង់ដែលបានផ្តល់ឱ្យលំនាំដើម (LGD'); និង

- ការប៉ះពាល់តាមលំនាំដើម (EAD)។

PD គឺជាការប៉ាន់ប្រមាណនៃលទ្ធភាព នៃការលំនាំដើមតាមរយៈពេលវេលាដែលបានកំណត់។ វាគឺត្រូវបានប៉ាន់ស្មាននៅចំណុចមួយនៃការគណនាគឺផ្អែកលើគំរូវាយតម្លៃស្ថិតិ និងវាយតម្លៃដោយប្រើឧបករណ៍វាយតម្លៃដែលតម្រូវទៅតាមប្រភេទផ្សេងៗនៃសមភាគី និងការប៉ះពាល់។ គំរូស្ថិតិទាំងនេះគឺផ្អែកលើទិន្នន័យលើទីផ្សារ (កន្លែងដែលមាន) ក៏ដូចជាទិន្នន័យខាងក្នុងដែលមានទាំងកត្តាបរិមាណ និងគុណភាព។ PD ត្រូវបានប៉ាន់ប្រមាណដោយពិចារណាលើកាលកំណត់នៃកិច្ចសន្យានៃការប៉ះពាល់ និងអត្រាការបង់ប្រាក់ជាមុនដែល បានប៉ាន់ស្មាន។ ការប៉ាន់ប្រមាណគឺផ្អែកលើលក្ខខណ្ឌបច្ចុប្បន្នដែលកែសម្រួលដើម្បីយកទៅក្នុងគណនីប៉ាន់ស្មាននៃលក្ខខណ្ឌនាពេលអនាគតដែលនឹងប៉ះពាល់ដល់ PD។ រាល់របាយការណ៍ទិន្នន័យសហិរញ្ញវត្ថុរបស់ធនាគាគឺត្រូវបានកំណត់នឹងដាក់ចេញទៅតាមយុទ្ធសាស្រ្ត របស់ធនាគារ។

LGDគឺជាការប៉ាន់ប្រមាណនៃការបាត់បង់ដែលកើតឡើងតាមលំនាំដើម។ វាត្រូវបានផ្អែកលើភាពខុសគ្នារវាងលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលដល់ពេលកំណត់ និងលំហូរសាច់ប្រាក់ដែលអ្នកផ្តល់ប្រាក់កម្ចី រំពឹងថានឹងទទួលបានដោយគិតពីលំហូរសាច់ប្រាក់ពីវត្ថុបញ្ចាំណាមួយ។ គំរូLGDសម្រាប់ទ្រព្យសកម្មដែលគ្មានសុវត្ថិភាពពិចារណាលើពេលវេលានៃការងើបឡើងវិញ អត្រានៃការងើបឡើងវិញ និងអតីតភាពនៃការទាមទារការគណនា គឺនៅលើមូលដ្ឋានលំហូរសាច់ប្រាក់បញ្ចុះតម្លៃ ដែលលំហូរសាច់ប្រាក់ត្រូវបានបញ្ចុះតម្លៃដោយ ER ដើមទុនប្រាក់កម្ចីដែលបានផ្តល់ជូនដោយសាច់ប្រាក់របស់ធនាគារ។

EAD គឺជាការប៉ាន់ប្រមាណ នៃការប៉ះពាល់នៅកាលបរិច្ឆេទលំនាំដើមនាពេលអនាគតដោយគិតគូរអំពីការផ្លាស់ប្តូរដែលរំពឹងទុកនៅក្នុងការប៉ះពាល់បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ រួមទាំងការសងប្រាក់ដើម និងការប្រាក់នឹងការដកប្រាក់ដែលរំពឹងទុកលើមធ្យោបាយដែលបានសន្យា។វិធីសាស្រ្តគំរូរបស់ធនាគារសម្រាប់EAD ឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរដែលរំពឹងទុកនៅក្នុងសមតុល្យ ដែលនៅសល់ក្នុងរយៈពេលពេញមួយជីវិតនៃការប៉ះពាល់ប្រាក់កម្ចីដែលត្រូវបានអនុញ្ញាតដោយលក្ខខណ្ឌនៃកិច្ចសន្យាបច្ចុប្បន្ន ដូចជាទម្រង់រំលោះ ការសងប្រាក់មុន ឬ ការទូទាត់លើសការផ្លាស់ប្តូរការប្រើប្រាស់ការសន្យាដែលមិនបានដកចេញ និងសកម្មភាពកាត់បន្ថយឥណទាន។ បានយកមុនពេលលំនាំដើម គឺធនាគារប្រើគំរូ EAD ដែលឆ្លុះបញ្ចាំងពីលក្ខណៈនៃផលប័ត្រ។

ធនាគារវាស់វែងECLគឺដោយពិចារណាលើហានិភ័យនៃការខកខានក្នុងរយៈពេលនៃកិច្ចសន្យាអតិបរមាដែលអង្គភាពត្រូវបានប៉ះពាល់នឹងហានិភ័យឥណទាន និងមិនមែនជារយៈពេលវែងជាងនេះ។ ទោះជាយ៉ាងណាក៏ដោយ សម្រាប់ឧបករណ៍ហិរញ្ញវត្ថុដូចជា បរិក្ខារឥណទានបង្វិល ដែលរួមមានទាំងប្រាក់កម្ចី និងសមាសភាគការប្តេជ្ញាចិត្តដែលមិនទាន់បានទាញសមត្ថភាពក្នុងកិច្ចសន្យារបស់ធនាគារក្នុងការទាមទារការទូទាត់សងនិងលុបចោលការសន្យាដែលមិនបានដកចេញនិងមិនកំណត់ការប្រឈមមុខ ជានឹងការបាត់បង់ឥណទានរបស់ធនាគារចំពោះរយៈពេលជូនដំណឹងតាមកិច្ចសន្យានោះទេ។ តែសម្រាប់ឧបករណ៍ហិរញ្ញវត្ថុបែបនេះ ធនាគារវាស់វែង ECL ក្នុងរយៈពេលដែលវាប្រឈមនឹងហានិភ័យឥណទានហើយ ECL នឹងមិនត្រូវបានកាត់បន្ថយដោយសកម្មភាពគ្រប់គ្រងហានិភ័យឥណទាន បើទោះបីជារយៈពេលនោះលាតសន្ធឹងលើសពីរយៈពេលកិច្ចសន្យាអតិបរមាក៏ដោយ។ ឧបករណ៍ហិរញ្ញវត្ថុទាំងនេះមិនមានរយៈពេលកំណត់ ឬរចនាសម្ព័ន្ធនៃការសងវិញទេហើយមានរយៈពេលខ្លីនៃការលុបចោលកិច្ចសន្យា។ ទោះជាយ៉ាងណាក៏ដោយធនាគារគឺមិនអនុវត្តក្នុងការ

គ្រប់គ្រងប្រចាំថ្ងៃធម្មតានៃសិទ្ធិកិច្ចសន្យាក្នុងការលុបចោលឧបករណ៍ហិរញ្ញវត្ថុទាំងនេះទេ។ នេះគឺដោយសារតែឧបករណ៍ហិរញ្ញវត្ថុទាំងនេះត្រូវបានគ្រប់គ្រងលើមូលដ្ឋានសមូហភាព ហើយត្រូវបានលុបចោលលុះត្រាតែធនាគារបានដឹងអំពីការកើនឡើងនៃហានិភ័យឥណទាននៅកម្រិតមូលដ្ឋាន។ រយៈពេលវែងជាងនេះត្រូវបានប៉ាន់ប្រមាណដោយគិតគូរពីសកម្មភាពគ្រប់គ្រងហានិភ័យឥណទាន ដែលធនាគាររំពឹងថានឹងចាត់វិធានការដើម្បីកាត់បន្ថយ ECL ឧ. ការកាត់បន្ថយដែនកំណត់ ឬលុបចោលការសន្យាបឥណទាន។

ការគណនាECLសម្រាប់គោលបំណងគណនេយ្យគឺខុសពីការគណនា ECL សម្រាប់គោលបំណងនិយតកម្ម ទោះបីជាធាតុបញ្ចូលជាច្រើនដែលប្រើគឺស្រដៀងគ្នាក៏ដោយ។ ធនាគារបានធានាថាវិធីសាស្រ្តសមស្របត្រូវបានប្រើប្រាស់នៅពេលគណនា ECL សម្រាប់គោលបំណងគណនេយ្យនិងបទប្បញ្ញត្តិ។ ដោយភាពខុសគ្នាសំខាន់រវាងវិធីសាស្រ្តដែលប្រើដើម្បីការវាស់ ECL ស្របតាម CIFRS No.9 ធៀបនឹងវិធីដែលត្រូវបានអនុវត្តសម្រាប់គោលបំណងបទប្បញ្ញត្តិដែលត្រូវយកមកអនុវត្តគឺ៖

- ភាគរយនៃការផ្តល់ដោយការចាត់ថ្នាក់ដោយផ្អែកលើប្រាក់កម្ចីរយៈពេលខ្លី/ វែង
- ចំនួនថ្ងៃដែលហួសកំណត់
- ការសម្លឹងទៅមុខនៃកត្តាម៉ាក្រូសេដ្ឋកិច្ច
- ប្រូបាប៊ីលីតេនៃអត្រាការងើបឡើងវិញតាមលំនាំដើម និងជាប្រវត្តិសាស្ត

ការវាស់វែងនៃ ECL គឺផ្អែកលើប្រូបាប៊ីលីតេទម្ងន់នៃការបាត់បង់ឥណទានជាមធ្យម។ ជាលទ្ធផល ការវាស់វែងនៃប្រាក់ឧបត្ថម្ភការខាតបង់គួរតែដូចគ្នា ដោយមិនគិតពីថាតើវាត្រូវបានវាស់វែងលើមូលដ្ឋានបុគ្គល ឬជាមូលដ្ឋានសមូហភាព (ទោះបីជាការវាស់វែងលើមូលដ្ឋានសមូហភាព គឺ ជាក់ស្តែងជាងសម្រាប់ផលប័ត្រធំនៃវត្ថុ)ទាក់ទងទៅនឹងការវាយតម្លៃថាតើមានការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទាន អាចចាំបាច់ក្នុងការអនុវត្តការវាយតម្លៃលើមូលដ្ឋានសមូហភាព។

### *សំវិធានធនបន្ថែមពីអ្នកគ្រប់គ្រង*

នៅឆ្នាំ2023 ជាលទ្ធផលនៃការវិភាគព័ត៌មានឆ្ពោះទៅមុខនៅតែមិនជាប់ទាក់ទងគ្នា ដូច្នេះហើយអ្នកគ្រប់គ្រងបានសម្រេចចិត្តប្រើជាមធ្យម 7ឆ្នាំ ឆ្ពោះទៅមុខនៃវិស័យនីមួយៗ ហើយអនុវត្តជាអត្រា PD ដើម្បីសម្របទៅនឹងស្ថានភាពបច្ចុប្បន្ន នៅឆ្នាំ2022 អ្នកគ្រប់គ្រងបានសម្រេចចិត្តប្រើអត្រា PAR 30ថ្ងៃ នៃវិស័យទាំងនោះជាមូលដ្ឋានសម្រាប់ការគ្រប់គ្រងត្រួតលើគ្នាដើម្បីឆ្លុះបញ្ចាំងពី ភាពមិនប្រាកដប្រជាសេដ្ឋកិច្ច។

ហានិភ័យទីផ្សារគឺជាហានិភ័យដែលមានការផ្លាស់ប្តូរតម្លៃទីផ្សារ- ឧទាហរណ៍ អត្រាការប្រាក់អត្រាប្តូររូបិយប័ណ្ណបរទេស និងតម្លៃមូលធន នឹងមានផលប៉ះពាល់ដល់ប្រាក់ចំណូលរបស់ធនាគារ ឬតម្លៃនៃការកាន់កាប់ឧបករណ៍ហិរញ្ញវត្ថុ។គោលបំណងនៃការគ្រប់គ្រងហានិភ័យទីផ្សារគឺដើម្បីគ្រប់គ្រងនិងជាការត្រួតពិនិត្យហានិភ័យទីផ្សារតាមប៉ារ៉ាម៉ែត្រដែលអាចទទួលយកបានខណៈពេលដែលមានការបង្កើននូវប្រសិទ្ធភាពក្នុងការទទួលបានចំណូលមកវិញក្នុងហានិភ័យទីផ្សារ។

### *ហានិភ័យអត្រាការប្រាក់*

ហានិភ័យអត្រាការប្រាក់ គឺសំដៅលើការខាតបង់នូវប្រាក់ចំណូលការប្រាក់សុទ្ធ ដោយសារតែការប្រែប្រួលនៃកម្រិតអត្រាការប្រាក់និងការផ្លាស់ប្តូរនៅក្នុងសមាសភាពនៃទ្រព្យសកម្មនិងបំណុល។ គឺជាហានិភ័យអត្រាការប្រាក់ត្រូវបានគ្រប់គ្រងតាមរយៈការត្រួតពិនិត្យយ៉ាងហ្មត់ចត់ លើចំណូលនៃការបណ្តាក់ទុន តម្លៃទីផ្សារ តម្លៃ

ដើមនៃមូលនិធិសក្តានុពលនៃការធ្លាក់ចុះចំណូលការប្រាក់សុទ្ធ បណ្តាលមកពីការប្រែប្រួលនៃអត្រាការប្រាក់ដែលខុសប្រក្រតី បានត្រួតពិនិត្យដោយធៀបទៅនឹងកម្រិតអាចទទួលយកបាននៃហានិភ័យការប្រាក់។

*កំណែលទម្រង់គោលការណ៍អត្រាការប្រាក់*

កំណែលទម្រង់មូលដ្ឋាននៃអត្រាការប្រាក់គោលកំពុងត្រូវបានអនុវត្តជាសកលរួមទាំងការជំនួសអត្រាការប្រាក់អន្តរធនាគារមួយចំនួន (BORS) ជាមួយនឹងអត្រាស្ទើរតែគ្មានហានិភ័យ ដែលហៅថាកំណែទម្រង់ធនាគារទទួលរងផលប៉ះពាល់មួយចំនួនទៅលើ IBOPs ដាក់លាក់ទៅលើឧបករណ៍ទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួនដែលនឹងត្រូវបានកែទម្រង់ជាផ្នែកមួយនៃការផ្តួចផ្តើមទូទាំងទីផ្សារទាំងនេះ។ បើគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ការប៉ះពាល់របស់ធនាគារទាក់ទិននឹង IBOR គឺជាការប្រឈមផ្អែកលើសន្ទស្សន៍ LIBOR ជាប្រាក់ដុល្លារអាមេរិកបីខែប្រាំមួយខែ និងដប់ពីខែ។ ការកំណត់ទាំងនេះនឹងឈប់ផ្តល់ជូន ឬលែងជាតំណាង បន្ទាប់ពីថ្ងៃទី30 ខែមិថុនា ឆ្នាំ 2023 ដូចដែលបានប្រកាសដោយអាជ្ញាធរប្រតិបត្តិហិរញ្ញវត្ថុ (FCA) ហើយជាអត្រាយោងជំនួស សម្រាប់ប្រាក់ដុល្លារអាមេរិក LIBOR គឺ SOFR។ ធនាគារកំពុងស្ថិតក្នុងដំណើរការកែប្រែ ឬរៀបចំធ្វើវិសោធនកម្ម លក្ខខណ្ឌនៃកិច្ចសន្យា ដើម្បីឆ្លើយតបទៅនឹងកំណែទម្រង់ IBOR ហើយនៅតែមានភាពមិនច្បាស់លាស់អំពី ពេលវេលា និងវិធីសាស្ត្រនៃការផ្លាស់ប្តូរនៅក្នុងយុត្តាធិការមួយចំនួនដែលធនាគារធ្វើប្រតិបត្តិការ។

ហានិភ័យចម្បងដែលធនាគាររងផលប៉ះពាល់នៃកំណែទម្រង់ BOR គឺផលប៉ះពាល់លើប្រតិបត្តិការ។ ឧ. ការចចារឡើងវិញនៃកិច្ចសន្យាឥណទាន និងបុរេប្រទានតាមរយៈការចចារទ្វេភាគីជាមួយអតិថិជនការធ្វើបច្ចុប្បន្នភាពលក្ខខណ្ឌកិច្ចសន្យាការធ្វើបច្ចុប្បន្នភាពប្រព័ន្ធដែលប្រើខ្សែកោង IBOR និងការពិនិត្យឡើងវិញនូវការគ្រប់គ្រងប្រតិបត្តិការដែលទាក់ទងទៅនឹងកំណែទម្រង់នេះ។ ហានិភ័យហិរញ្ញវត្ថុភាគច្រើនគឺ ត្រូវបានកំណត់ត្រឹមហានិភ័យអត្រាការប្រាក់។ សម្រាប់កិច្ចសន្យាចាស់ដែលពាក់ព័ន្ធនឹង LIBOR ហើយត្រូវដល់កាលកំណត់បន្ទាប់ពីថ្ងៃអវសាននៃអត LIBOR។ អត្រាយោងផ្សេងទៀតសម្រាប់ជំនួស LIBOR អាមេរិកគឺជា The Secured Overnight Financing Rate (SOFR) ដំណើរការលើការផ្លាស់ប្តូរលើលក្ខខណ្ឌកិច្ចសន្យានៃបំណុលហិរញ្ញវត្ថុរបស់ធនាគារពាក់ព័ន្ធនឹង LIBOR របស់ អាមេរិកដើម្បីដាក់បញ្ចូលនូវអត្រាការប្រាក់ប្រៀបធៀបថ្មី ពុំទាន់ចប់រួចរាល់នៅឡើយទេ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2023។

*ហានិភ័យលើការប្តូររូបិយប័ណ្ណបរទេស*

ធនាគារដំណើរការក្នុងព្រះរាជាណាចក្រកម្ពុជា ហើយធ្វើប្រតិបត្តិការជាចម្បងជាប្រាក់ដុល្លារអាមេរិក ជារៀលខ្មែរ និងបាតថៃ។ ហានិភ័យលើការប្តូររូបិយប័ណ្ណបរទេស គឺជាហានិភ័យដែលតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុមានការប្រែប្រួលបណ្តាលមកពីការប្រែប្រួលនៃអត្រាប្តូររូបិយប័ណ្ណបរទេស។

ហានិភ័យសាច់ប្រាក់ងាយស្រួលគឺជា៖ ហានិភ័យដែលធនាគារអាចនឹងត្រូវជួបផលលំបាកក្នុងការបំពេញកាតព្វកិច្ចពាក់ព័ន្ធនឹងបំណុលហិរញ្ញវត្ថុរបស់ខ្លួន ដែលត្រូវបានទូទាត់តាមរយៈជាសាច់ប្រាក់ ឬតាមរយៈជាទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត។ ហានិភ័យសាច់ប្រាក់ងាយស្រួលកើតឡើងពីភាពមិនស៊ីគ្នាទៅនឹងពេលវេលានិងចំនួនលំហូរទឹកប្រាក់ដែលមាននៅក្នុងប្រតិបត្តិការ និងការវិនិយោគរបស់ធនាគារ។

*ការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល*

ធនាគារគ្រប់គ្រងសាច់ប្រាក់ងាយស្រួលរបស់ខ្លួនតាមរយៈ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្មបំណុលដែលទទួលខុសត្រូវក្នុងការបង្កើតគោលនយោបាយសាច់ប្រាក់ងាយស្រួលនិងជាត្រួតពិនិត្យសាច់ប្រាក់ងាយស្រួលជាប្រចាំ។ ដែលតម្រូវការទ្រព្យសកម្មងាយស្រួលអប្បបរមាត្រូវបានបង្កើតឡើងដើម្បីធានាថាអនុបាតនៃទ្រព្យសកម្មងាយស្រួល និងបំណុលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវទទួលបានកម្រិតអប្បបរមាគ្រប់ពេលវេលា។ តារាងខាងក្រោមសង្ខេបពីទ្រព្យសកម្ម និងបំណុលរបស់ធនាគារ ដោយផ្អែកលើឥណប្រតិទានតាមកិច្ចសន្យាដែលនៅសល់។ លំហូរទឹកប្រាក់ដែលបានរំពឹងទុកលើទ្រព្យសកម្ម និងបំណុលទាំងនេះអាចខុសជាសារវន្តពីអ្វីដែលបានបង្ហាញនៅក្នុងតារាងតុល្យការ។ ឧទាហរណ៍ៈ ប្រាក់បញ្ញើរបស់អតិថិជនមិនត្រូវបានរំពឹងថានឹងត្រូវដកបានភ្លាមៗនោះទេ។

ហានិភ័យប្រតិបត្តិការគឺជាហានិភ័យនៃការបាត់បង់ផ្ទាល់ ឬជាប្រយោលដែលកើតមានឡើងពីការខ្វះខាតឬការអនុវត្តមិនមានប្រសិទ្ធភាពនូវនីតិវិធីដំណើរការផ្ទៃក្នុងបុគ្គលិក ឬប្រព័ន្ធឬពីកត្តាខាងក្រៅផ្សេងទៀត ហានិភ័យនេះត្រូវបានគ្រប់គ្រងតាមរយៈការបង្កើតប្រព័ន្ធដំណើរការគ្រប់គ្រងប្រតិបត្តិការ ការត្រួតពិនិត្យ និងការរាយការណ៍ឱ្យបានត្រឹមត្រូវពីសកម្មភាពអាជីវកម្មតាមរយៈការគ្រប់គ្រង និងត្រួតពិនិត្យពីគណៈគ្រប់គ្រងជាន់ខ្ពស់។ ទាំងនេះរួមមានហានិភ័យខាងផ្នែកច្បាប់តាមច្បាប់នៃការអនុលោមភាពគឺជា (ផលអាក្រក់) តាមគណនេយ្យ និងការក្លែងបន្លំ។ ការគ្រប់គ្រងលើហានិភ័យប្រតិបត្តិការ របស់ធនាគារតម្រូវឱ្យបង្កើតនូវបាននូវរចនាសម្ព័ន្ធតួនាទី និងវិធីសាស្ត្រនៃការគ្រប់គ្រងរបស់អង្គភាពឱ្យបានច្បាស់លាស់។ គោលការណ៍ និងវិធានការត្រួតពិនិត្យផ្ទៃក្នុងជាច្រើនត្រូវបានអនុវត្តរួមមានការបង្កើតអ្នកមានសិទ្ធិចុះហត្ថលេខា ជាប្រព័ន្ធត្រួតពិនិត្យយ៉ាងហ្មត់ចត់ជាការរៀបចំនូវនីតិវិធី និងឯកសារយោងនានាព្រមទាំងការអនុវត្តតាមបទប្បញ្ញត្តិ និងតម្រូវការតាមច្បាប់នានា។ ដោយដំណើរការទាំងនេះគឺ ត្រូវបានត្រួតពិនិត្យជាប្រចាំឆ្នាំដើម្បីឆ្លើយតបទៅនឹងហានិភ័យប្រតិបត្តិការដែលអាចកើតឡើងនៅក្នុងប្រតិបត្តិការអាជីវកម្មរបស់ធនាគារ។

**<u>ការគ្រប់គ្រងដើមទុន</u>**

***(i). បទប្បញ្ញត្តិដើមទុន***

គោលដៅរបស់ធនាគារក្នុងការគ្រប់គ្រងដើមទុនមានន័យទូលំទូលាយជាងទៅនិង "មូលធនដែលបង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ"។ ការគ្រប់គ្រងដើមទុនមានដូចខាងក្រោម៖

- អនុលោមតាមតម្រូវការដើមទុនដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា
- ការពារលទ្ធភាពរបស់ធនាគារដើម្បីបន្តនិរន្តរ៍ភាពអាជីវកម្ម ដូចនេះធនាគារគឺ៖ អាចនឹងបន្តផ្តល់ផលប្រយោជន៍ ដល់ភាគទុនិក និងអត្ថប្រយោជន៍របស់ភាគីដែលពាក់ព័ន្ធនឹងធនាគារ និង
- រក្សាមូលដ្ឋានដើមទុនរឹងមាំដើម្បីគាំទ្រដល់ការអភិវឌ្ឍអាជីវកម្ម។

គោលនយោបាយរបស់ធនាគារគឺ ធានាឱ្យបាននូវមូលដ្ឋានដើមទុនរឹងមាំ ដើម្បីរក្សានូវទំនុកចិត្តទីផ្សារទូទៅ និងដើម្បីធានាស្ថេរភាពនៃការអភិវឌ្ឍន៍យូរអង្វែងរបស់អាជីវកម្ម។ផលប៉ះពាល់ទៅលើកម្រិតដើមទុនលើភាគលាភរបស់ភាគទុនិកក៏ត្រូវបានទទួលស្គាល់ ហើយធនាគារបានទទួលស្គាល់នូវតម្រូវការដើម្បីធានាឱ្យបាននូវតុល្យភាពរវាងភាគលាភខ្ពស់ដែលអាចនឹងកើតមានឡើងជាមួយនិងប្រាក់បម្រុងកម្រិតខ្ពស់រួមទាំងជាការអត្ថប្រយោជន៍និងការធានាដែលផ្តល់ដោយស្ថានភាពដើមទុនល្អ។

ដើមទុនតាមបទប្បញ្ញត្តិត្រូវបានគណនាឡើងដោយផ្អែកតាមសេចក្តីណែនាំដែលចេញផ្សាយ ដោយធនាគារ

ជាតិនៃកម្ពុជា ដែលអាចមានភាពខុសគ្នាទៅលើគោលការណ៍សំខាន់ខ្លះៗបើប្រៀបធៀបទៅនឹងគោលការណ៍ដែលបានទទួលស្គាល់ជាទូទៅ ដែលស្ថាប័នហិរញ្ញវត្ថុនៅប្រទេសដទៃបានអនុវត្ត។ ដូច្នេះព័ត៌មានអំពីដើមទុនខាងលើមិនសមស្របសម្រាប់អ្នកប្រើប្រាស់ដែលមិនបានទទួលព័ត៌មាន អំពីសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

*(ii). ការគ្រប់គ្រងហានិភ័យមូលធន*

ហានិភ័យមូលធនបានវាស់វែង និងត្រួតពិនិត្យដោយប្រើដែនកំណត់ ដែលបានគណនាស្របតាមលក្ខខណ្ឌតម្រូវការរបស់ធនាគារជាតិនៃកម្ពុជា។ នៅថ្ងៃទី2 ខែកុម្ភៈ ឆ្នាំ2018 ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសស្តីពីការកំណត់ទ្រនាប់ដើមទុន (Capital Buffer) សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ ដោយយោងតាមមាត្រា22 នៃប្រកាសនេះ គ្រឹះស្ថានទាំងអស់ត្រូវគោរពតាមបទប្បញ្ញត្តិទាក់ទងទៅនឹងការរក្សាទ្រនាប់ដើមទុនយ៉ាងហោចណាស់ឱ្យបាន 50% នៃដើមទុនសរុបគិតត្រឹមថ្ងៃទី1 ខែមករា ឆ្នាំ2019 និងអនុវត្តឱ្យបានយ៉ាងពេញលេញ គិតត្រឹមថ្ងៃទី1 ខែមករា ឆ្នាំ2020។

នៅថ្ងៃទី7 ខែមីនា ឆ្នាំ2018 ធនាគារជាតិនៃកម្ពុជា បានចេញសារាចរណែនាំស្តីពីការអនុវត្តប្រកាសស្តីពីការកំណត់ទ្រនាប់ដើមទុនសម្រាប់គ្រឹះស្ថានធនាគារ និងជាហិរញ្ញវត្ថុដែលបានកំណត់អនុបាតនៃទ្រនាប់ដើមទុនខោនជើស៊ីឃ្លីខល (Countercyclical Capital Buffer) ចំនួន 0% រហូតដល់មានការជូនដំណឹងជាថ្មី។

បន្ទាប់មកនៅថ្ងៃទី១ខែមករា ឆ្នាំ2023 ធនាគារជាតិនៃកម្ពុជាបានចេញសារាចរណ៍ណែនាំបន្ថែមគឺស្តីអំពីការអនុវត្តប្រកាសស្តីពីការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលជាគ្រឹះស្ថានដែលត្រូវបំពេញទ្រនាប់ដើមទុនខនស៊ើវេសិនតាមកម្រិតអនុបាត 1.25% និង 2.5% នៅត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 និងនៅត្រឹម ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023 រៀងគ្នា។ ចំពោះអនុបាតទ្រនាប់ដើមទុនតោនធើស៊ីខល (countercyclical Capital buffer) គ្រឹះស្ថានត្រូវរក្សាក្នុងកម្រិត % ដដែល។

**៣.៣.២. ផលប្រយោជន៍ធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់អ្នកប្រើប្រាស់**

សវនកម្មរបាយការណ៍ហិរញ្ញវត្ថុ ផ្តល់ឱ្យអ្នកប្រើប្រាស់នូវទំនុកចិត្តលើភាពត្រឹមត្រូវនិងភាពជឿជាក់នៃព័ត៌មានដែលបានបង្ហាញ។ ការធានានេះគឺមានសារៈសំខាន់សម្រាប់អ្នកពាក់ព័ន្ធផ្សេងៗរួមទាំងជាវិនិយោគិនម្ចាស់បំណុល និងស្ថាប័ននិយតកម្ម ដែលពឹងផ្អែកលើរបាយការណ៍ទាំងនេះដើម្បីធ្វើជាការសម្រេចចិត្តប្រកបដោយការយល់ដឹង។ អត្ថប្រយោជន៍សម្រាប់អ្នកប្រើប្រាស់រួមមាន៖

- បង្កើនភាពជឿជាក់និងតម្លាភាព៖ គឺសវនកម្មផ្តល់នូវការផ្ទៀងផ្ទាត់ឯករាជ្យ នៃរបាយការណ៍ហិរញ្ញវត្ថុបង្កើនភាពជឿជាក់ និងភាពជឿជាក់របស់ពួកគេ។
- ធ្វើការសម្រេចចិត្តបានប្រសើរឡើង៖ អ្នកប្រើប្រាស់គឺអាចធ្វើការសម្រេចចិត្តដែលមានព័ត៌មានបន្ថែមទៀតអំពីការវិនិយោគប្រាក់កម្ចីនិងបញ្ហាហិរញ្ញវត្ថុផ្សេងទៀតដោយផ្អែកលើរបាយការណ៍ដែលបានធ្វើសវនកម្ម
- ការកាត់បន្ថយហានិភ័យ៖ សវនកម្មជួយកំណត់ហានិភ័យដែលអាចកើតមានដូចជាការក្លែងបន្លំ ឬជាកំហុសដែលអនុញ្ញាតឱ្យមានសកម្មភាពកែតម្រូវទាន់ពេលវេលា។
- ការអនុលោមតាមបទប្បញ្ញត្តិ៖ របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មបង្ហាញពីការអនុលោមទៅតាមស្តង់ដារគណនេយ្យ និងបទប្បញ្ញត្តិកាត់បន្ថយហានិភ័យនៃការពិន័យ។
- លទ្ធភាពទទួលបានហិរញ្ញប្បទាន៖ របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មគឺ អាចធ្វើឱ្យប្រសើរ

ឡើងនូវចំណាត់ថ្នាក់ឥណទានរបស់ក្រុមហ៊ុន និងធ្វើឱ្យវាកាន់តែងាយស្រួលក្នុងការធានាហិរញ្ញវត្ថុ។

- ការត្រួតពិនិត្យផ្ទៃក្នុងប្រសើរឡើង៖ ដំណើរការសវនកម្មអាចកំណត់អត្តសញ្ញាភាពទន់ខ្សោយក្នុងការគ្រប់គ្រងផ្ទៃក្នុង ដែលនាំទៅដល់ការកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុ។ ការយល់ដឹងកាន់តែច្បាស់អំពីសុខភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន៖ សវនកម្មផ្តល់នូវការយល់ដឹងអំពីដំណើរការនិងមុខតំណែងហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដោយជួយអ្នកប្រើប្រាស់វាយតម្លៃសុខភាពទូទៅរបស់វា។
- ការរកឃើញកំហុស និងការក្លែងបន្លំ៖ ដោយបង្ហាញពីកំហុសនិងការក្លែងបន្លំដែលអាចកើតមាននៅក្នុងកំណត់ត្រាហិរញ្ញវត្ថុការពារការខូចខាតនិងការខាតបង់បន្ថែមទៀត។ នឹងការគាំទ្រសម្រាប់ផែនការយុទ្ធសាស្ត្រព័ត៌មានហិរញ្ញវត្ថុដែលបានធ្វើសវនកម្មអាចមានតម្លៃសម្រាប់ការធ្វើផែនការយុទ្ធសាស្ត្រ និងការធ្វើការសម្រេចចិត្ត។ ទំនុកចិត្តទៅលើភាពត្រឹមត្រូវនៃការរាយការណ៍សវនកម្មបញ្ជាក់ថាតើព័ត៌មានហិរញ្ញវត្ថុត្រូវបានបង្ហាញដោយយុត្តិធម៌ និងត្រឹមត្រូវ។

ជាការពិតណាស់របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានទទួលស្គាល់ថាស្របទៅតាមស្តង់ដារ និងបានអនុលោមទៅតាមបទប្បញ្ញត្តិ និតិវិធីគោលការគណនេយ្យគឺមិនមានហានិភ័យខ្ពស់សម្រាប់អ្នកប្រើប្រាស់ខាងក្រៅនូវរបាការណ៍ហិរញ្ញវត្ថុទាំងអស់នេះ។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ក្រោយពីធ្វើការសិក្សាស្រាវជាវវាស់វែងពីវិធីសាស្ត្រវាយតម្លៃទៅលើរបាយការណ៍សវនកម្មហិរញ្ញវត្ថុរួមទាំងចំណុចផ្សេងៗ នៃរបាយការណ៍របស់ធនាគារ **អ៊ូរី (ខេមបូឌា) ម.ក** និងការធ្វើសវនកម្មរបស់សវនករឃើញថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គងនិងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់សវនករ។ ជាអំណះអំណាងសមហេតុផលគឺជាអំណះអំណាងមួយដែលមានកម្រិតខ្ពស់ប៉ុន្តែវាមិនអាចធានាថាគ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជាគឺអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុសអាចកើតឡើងដោយសារការក្លែងបន្លំឬកំហុសឆ្គងហើយត្រូវបានចាត់ទុកថាមានលក្ខណៈសារវន្តនៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងដោយឡែក ឬក៏រួមបញ្ចូលគ្នាអាចត្រូវបានរំពឹងទុកយ៉ាងសមហេតុផលថានឹងជះឥទ្ធិពលដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយការយោងទៅលើរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មនេះឡើយ។

ហេតុដូចនេះទើបអាចឱ្យយើងទាញបាន សម្មិទ្ធិកម្មមួយក្នុងការវាយតម្លៃ និងវិភាគទៅទៅលើចំណុចខ្លាំងនិងចំណុចខ្សោយរបស់ប្រព័ន្ធនៃការគ្រប់គ្រង។ ភាពខ្វះចន្លោះប្រហោងតិចតួចនៃការគ្រប់គ្រងគឺតែងតែកើតមានដោយជៀសមិនផុត។ ដូច្នេះខាងក្រោមនេះខ្ញុំនឹងធ្វើការលើកឡើងពីរចំណុចយកមកវិភាគគឺ៖

## ៤.១. ការវិភាគលើចំណុចខ្លាំង របស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវលម្អិតទៅលើ របាយការណ៍សនវកម្មហិរញ្ញវត្ថុនៅជំពូកទី៣ នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក រួចមកអាចឱ្យខ្ញុំមើលឃើញពីចំណុចខ្លាំងដែលធនាគារបានលើកយកមកអនុវត្តនោះ គឺការគ្រប់គ្រងទៅលើហានិភ័យហិរញ្ញវត្ថុដែលនៅក្នុងនោះគឺខ្ញុំសង្កេតឃើញថាធនាគារមានចំណុចល្អប្រសើរក្នុងការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុចំនួន៤គឺ៖

- ហានិភ័យឥណទាន
- ហានិភ័យទីផ្សារ
- ហានិភ័យសាច់ប្រាក់ងាយស្រួល និង
- ហានិភ័យប្រតិបត្តិការ

ដោយទាំងនេះអាចធ្វើឱ្យយើងកត់សម្គាល់ឃើញថាអ្នកគ្រប់គ្រងធនាគារគឺ មានគោលដៅចាត់វិធានការដើម្បីវាស់វែងនិងគ្រប់គ្រងនូវហានិភ័យដែលកើតឡើងនិងការគ្រប់គ្រងនូវដើមទុនរបស់ធនាគារ។ ដោយប្រើវិធីក្នុងការដាក់ជាក្រុមត្រូវបានត្រួតពិនិត្យជាប្រចាំដើម្បីធានាថាក្រុមនីមួយៗមានការបង្ហាញភាពដូចគ្នា។ជាការវាយតម្លៃហានិភ័យឥណទានត្រូវបានពិនិត្យ និងធ្វើបច្ចុប្បន្នភាពលើមូលដ្ឋានប្រចាំឆ្នាំ ហើយនៅក្នុងព្រឹត្តិការណ៍នៃការផ្លាស់ប្តូរលក្ខខណ្ឌកម្ចីរួមទាំងការពន្យារពេលនៃកម្ចីសាច់ប្រាក់របស់ធនាគារផងដែរ។

ធនាគារប្រើគោលនយោបាយណ៍និងការអនុវត្តជាច្រើនដើម្បីគ្រប់គ្រងហានិភ័យឥណទាន។ ជាទំនៀមទំលាប់ដែលបំផុតនៃការផ្តល់កម្ចីទាំងនេះគឺការយកជាវត្ថុបញ្ចាំសម្រាប់ប្រាក់កម្ចីដល់អតិថិជនដែលជាការអនុវត្តទូទៅធនាគារបានអនុវត្តគោលការណ៍ណែនាំស្តីពីភាពអាចទទួលយកបាននៃប្រភេទដាក់លាក់នៃវត្ថុបញ្ចាំ ការកាត់

បន្ថយហានិភ័យឥណទាន។ ប្រភេទវត្ថុបញ្ចាំសំខាន់ៗដែលធនាគារសម្រាប់ប្រាក់កម្ចីដល់អតិថិជនរួមមានដា ដី ផ្ទះ អគារ និងអចលនវត្ថុផ្សេងៗទៀត។ គោលនយោបាយរបស់ធនាគារគឺផ្តល់មូលនិធិរហូតដល់ទៅ 75% នៃតម្លៃវត្ថុបញ្ចាំ មិនមានការផ្លាស់ប្តូរនៅក្នុងគោលនយោបាយណ៍វត្ថុបញ្ចាំរបស់ធនាគារក្នុងអំឡុងឆ្នាំនោះទេ។

*ការប្រមូលផ្តុំហានិភ័យ*

ធនាគារប្រតិបត្តិនិងផ្តល់ប្រាក់កម្ចីនិងបុរេប្រទានដល់បុគ្គលឬសហគ្រាសក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារគ្រប់គ្រងដែនកំណត់និងគ្រប់គ្រងការប្រមូលផ្តុំហានិភ័យឥណទាននានា នៅពេលណាដែលពួកគេគឺត្រូវបានកំណត់អត្តសញ្ញាណថាអាចនឹងជាហានិភ័យដែលកើតមានឡើងនៅពេលខាងមុខដ៏ខ្លី។

ធនាគារតាមដានរាល់ទ្រព្យសកម្មហិរញ្ញវត្ថុដែលស្ថិតក្រោមលក្ខខណ្ឌតម្រូវនៃការចុះខ្សោយ ដើម្បីវាយតម្លៃថាតើមានការកើនឡើងគួរឱ្យកត់សម្គាល់នៃហានិភ័យឥណទានចាប់តាំងពីការទទួលស្គាល់ដំបូងប្រសិនបើមានការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទានធនាគារនិងវាស់វែងប្រាក់ឧបត្ថម្ភការខាតបង់ដោយផ្អែកទៅលើអាយុកាលជាសជាង ELC រយៈពេល១២ខែ។

ក). ហានិភ័យឥណទានគឺជាហានិភ័យៈនៃការខាតបង់ផ្នែកហិរញ្ញវត្ថុរបស់ធនាគារប្រសិនបើអតិថិជនឬភាគីម្ខាងទៀតមិនមានលទ្ធភាពបំពេញកាតព្វកិច្ចទៅតាមកិច្ចសន្យាហើយហានិភ័យជាចម្បងនេះគឺកើតចេញតាមរយៈការផ្តល់ឥណទាន និងបុរេប្រទានដល់អតិថិជនធនាគារនានា និងជាការវិនិយោគលើមូលបត្របំណុល។ សម្រាប់គោលបំណងរាយការណ៍អំពីការគ្រប់គ្រងហានិភ័យធនាគារគឺធ្វើការពិចារណា និងដាក់រួមបញ្ចូលនូវជាតុទាំ អស់នៃហានិភ័យឥណទានដែលប្រឈម ។. ហានិភ័យតាមកាតព្វកិច្ចរបស់បុគ្គលម្នាក់ៗ ហានិភ័យតាមវិស័យនិងប្រទេស។ ហានិភ័យឥណទានគឺជាការខាតបង់ចំណូល និងការខាតបង់ដើមកើតឡើងពីឥណទាននិងបុរេប្រទាន និងកិច្ចសន្យាកម្ចី ដោយសារអ្នកខ្ចី ឬសមភាគីខកខានមិនទូទាត់សង់។

ខ). ហានិភ័យទីផ្សារៈគឺហានិភ័យដែលមានការផ្លាស់ប្តូរតម្លៃទីផ្សារ ។. អត្រាការប្រាក់ អត្រាប្តូររូបិយប័ណ្ណបរទេសនិងតម្លៃមូលធននឹងមានផលប៉ះពាល់ដល់ប្រាក់ចំណូលរបស់ធនាគារ ឬតម្លៃនៃការកាន់កាប់ឧបករណ៍ គោលបំណងនៃការគ្រប់គ្រងហានិភ័យទីផ្សារ គឺដើម្បីគ្រប់គ្រងនិងត្រួតពិនិត្យហានិភ័យទីផ្សារតាមប៉ារ៉ាម៉ែត្រដែលអាចទទួលយកបាន ខណៈពេលដែលមានការបង្កើននូវប្រសិទ្ធភាពក្នុងការទទួលបានចំណូលមកវិញ។

គ). ហានិភ័យសាច់ប្រាក់ងាយស្រួលៈគឺជាហានិភ័យដែលធនាគារជួបផលលំបាក ក្នុងការបំពេញកាតព្វកិច្ចទាក់ទងនឹងបំណុលហិរញ្ញវត្ថុរបស់ខ្លួនដែលត្រូវបានទូទាត់តាមរយៈជាសាច់ប្រាក់ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត។ ហានិភ័យសាច់ប្រាក់ងាយស្រួលកើតឡើងពីភាពមិនស៊ីគ្នាទៅនឹងពេលវេលានិងចំនួនលំហូរទឹកប្រាក់ដែលមាននៅក្នុងប្រតិប្រត្តិការ និងការវិនិយោគរបស់ធនាគារ។

ឃ). ហានិភ័យប្រតិបត្តិការៈគឺជាហាភ័យការបាត់បង់ផ្ទាល់ ឬប្រយោលដែលកើតមានឡើងពីការខ្វះខាត ឬការអនុវត្តដោយគ្មានប្រសិទ្ធភាពនៃនីតិវិធីដំណើរការផ្ទៃក្នុងបុគ្គលិក ឬប្រព័ន្ធ ឬកត្តាខាងក្រៅ។ ហានិភ័យនេះត្រូវបានគ្រប់គ្រងតាមរយៈការបង្កើតប្រព័ន្ធដំណើរការគ្រប់គ្រងប្រតិបត្តិការការត្រួតពិនិត្យនិងការរាយការណ៍ឱ្យបានត្រឹមត្រូវពីសកម្មភាពអាជីវកម្មតាមរយៈការគ្រប់គ្រងនិងត្រួតពិនិត្យពីគណៈគ្រប់គ្រងជាន់ខ្ពស់។

ទាំងនេះរួមមានហានិភ័យទាំងផ្នែកច្បាប់ តាមច្បាប់នៃការអនុលោម (ផ្តល់អាក្រក់) តាមគណនេយ្យ និងការក្លែងបន្លំ។

ការគ្រប់គ្រងលើហានិភ័យប្រតិបត្តិការរបស់ធនាគារ តម្រូវឱ្យបង្កើតរចនាសម្ព័ន្ធតួនាទី និងវិធីសាស្ត្រ

នៃការគ្រប់គ្រងរបស់អង្គភាពឱ្យបានច្បាស់លាស់។ គោលការណ៍ និងវិធានការត្រួតពិនិត្យផ្ទៃក្នុងជាច្រើនត្រូវបានអនុវត្តរួមមានការបង្កើតអ្នកមានសិទ្ធិចុះហត្ថលេខាប្រព័ន្ធត្រួតពិនិត្យយ៉ាងហ្មត់ចត់ការរៀបចំនូវនីតិវិធីនិងឯកសារយោងនានា ព្រមទាំងការអនុវត្តតាមបទប្បញ្ញត្តិ និងតម្រូវការតាមច្បាប់នានា។

## ៤.២. វិភាគលើចំណុចខ្សោយ ឬខ្វះចន្លោះនៃការគ្រប់គ្រង

ដូចគ្នាទៅនឹងចំណុចខាងលើ នៃកិច្ចការស្រាវជ្រាវសវនកម្មរបាយការណ៍ហិរញ្ញវត្ថុលើចំណុចខ្លាំងរួចមកយើងក៏បានអង្កេតឃើញនិងចាប់អារម្មណ៍ទៅលើចន្លោះប្រហោងមួយចំនួននៃការគ្រប់គ្រងគឺទៅលើប្រព័ន្ធហិរញ្ញវត្ថុរបស់ធនាគារផងដែរ ដោយអាចជាហានិភ័យទាំងនោះរួមមានៈ

- ហានិភ័យឥណទានដែលធនាគាបានផ្តល់ជូនអតិថជន ហើយវាគឺស្ថិននៅក្រោមលក្ខខណ្ឌឥណទានដែលស្ថិតនៅក្នុងចំណាត់ថ្នាក់ត្រូវបានការពារនាពេលបច្ចុប្បន្ន ដោយវាគឺបង្ហាញពីភាពទន់ខ្សោយដែលអាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ការទូទាត់សងរបស់កូនបំណុលនៅកាលបរិយច្ឆេទនាពេលអនាគត់ ប្រសិនបើវាមិនបានកែតម្រូវឱ្យបានទាន់ពេលវេលានិងជាការយកចិត្តទុកដាក់ពីគ្រឹះស្ថានធនាគារ អ៊ូរី (ខេមបូឌា) ម.ក។

- ហានិភ័យឥណទានដែលត្រូវបានចាត់ថ្នាក់ថាជាការបាត់បង់នៅពេលដែលវាមិនអាចប្រមូលបានមកវិញនូវការទូទាត់សងឬមិនអាចប្រមូលបានសោះពីសមភាគីនូវចំនួនដែលនៅសល់សម្រាប់រាល់កម្ចីទាំងឡាយដែលបានផ្តល់ដោយធនាគារនូវរាល់កម្ចីទាំងអស់នោះ។

- ហានិភ័យឥណទានដែលមិនត្រូវបានការពារគ្រប់គ្រាន់ដោយអាជីវកម្មបច្ចុប្បន្នឬ ស្ថានភាពហិរញ្ញវត្ថុ និងលទ្ធភាពសងរបស់កូនបំណុលទេ។ គឺថានិយាយឱ្យចំទៅប្រភពដើមនៃការសងបំណុលគឺមិនគ្រប់គ្រាន់ដើម្បីទូទាត់បំណុលនោះទេ ដោយមិនគិតអំពីប្រាក់ចំណូលដែលបានមកពីប្រភពបន្ទាប់បន្សំដូចជាការលក់ទ្រព្យបញ្ចាំរបស់អតិថិជនទូទៅ ឬកម្ចីដទៃទៀតឡើយ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

ការសិក្សាស្រាវជ្រាវទាំងមូលគឺក្រោយពីបានវាយតម្លៃ និងវាស់វែងទៅលើរបាយការណ៍នៃការបានធ្វើសនវនកម្មហិរញ្ញវត្ថុរបស់ធនាគារ **អ៊ូរី (ខេមបូឌា) ម.ក** រួចមកគឺអាចឱ្យខ្ញុំទាញបាននូវសេចក្តីសន្និដ្ឋានដោយភ្ជាប់ជាមួយការប៉ាន់ប្រមាណដូចខាងក្រោម៖

៥.១. សេចក្តីសន្និដ្ឋាន

ធនាគារ អ៊ូរី (ខេមបូឌា) ម.ក បានធ្វើការគ្រប់គ្រងប្រព័ន្ធប្រតិបត្តិការសមស្របនៃគោលនយោបាយគណនេយ្យដែលធនាគារបានអនុវត្ត និងភាពសមហេតុផល នៃការប៉ាន់ស្មានគណនេយ្យ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធនានា ដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។ រួមនឹងការប្រើប្រាស់មូលដ្ឋាននិរន្តរ៍ភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រងហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានគឺធ្វើការសន្និដ្ឋានថាតើភាពមិនប្រាកដប្រជាជាសារវន្តបានកើតមានឡើងពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ឬលក្ខខណ្ឌដែលអាចបង្កឱ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ធនាគារ ដើម្បីបន្តនិរន្តរ៍ភាពអាជីវកម្មដែរ ឬទេ? ប្រសិនបើយើងខ្ញុំធ្វើការសន្និដ្ឋានថា មានអត្ថិភាពនៃភាពមិនប្រាកដជាសារវន្តយើងខ្ញុំចាំបាច់ត្រូវទាញចំណាប់អារម្មណ៍ នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំលើការលាតត្រដាងព័ត៌មាន ដែលពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬ ប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់គឺ ខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលកើតមានបញ្ហា។ ការសន្និដ្ឋានរបស់ខ្ញុំគឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមស្របតាមកាលបរិយច្ឆេទនៃរបាយការណ៍សវនកម្មរបស់ខ្ញុំ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឱ្យធនាគារបញ្ឈប់និរន្តរ៍ភាពនៃអាជីវកម្មរបស់ធនាគារ ឬស្ថាបនអាជីវកម្មផ្សេងៗផងដែល។

ធ្វើការវាយតម្លៃលើការបង្ហាញទម្រង់និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូលគឺដោយរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

ការវិនិច្ឆ័យដោយយោងតាមរបាយការណ៍សវនកម្មរបស់សវនករគឺក៏បានលាតត្រដាងនូវរបាយការណ៍មួយដែលមាននិរន្តរ៍ភាព ដែលនិងជាការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលដូចទៅនឹងការលាតត្រដាងនូវរបាយការណ៍ត្រួតពិនិត្រផ្ទៃក្នុងដូចតទៅនេះ។ យើងខ្ញុំផ្តល់ព័ត៌មានក្នុងចំណោមបញ្ហាផ្សេងៗជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ចស្តីពីវិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងជាការរកឃើញបញ្ហាជាសារវន្តដោយរួមបញ្ចូលទាំងចំណុចខ្វះខាត ជាសារវន្តក្នុងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្មនៃរបាយការណ៍សវនកម្មហិរញ្ញវត្ថុនេះ។

## ៥.២. ការផ្តល់អនុសាសន៍

ដោយស្របទៅតាមការស្រាវជ្រាវឃើញថារបាយការណ៍នៃសវនកម្មលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ទៅលើប្រធានបទខាងលើរួចមកអាចឱ្យខ្ញុំទាញបាននូវការផ្តល់ជាអនុសាសន៍ចូលរួមជាទន់ក្នុងការកែលម្អ នូវរាល់និតិវិធីនៃប្រតិបត្តិការរបស់ប្រព័ន្ធគ្រប់ហានិភ័យដែលអាចកើតមានឡើង

ជាយថាហេតុណាមួយក្នុងប្រតិបត្តិការរបស់ធនាគារផងដែរ។ រួមទាំងធ្វើឱ្យប្រសើរឡើង និងរីកចម្រើនទៅមុខជានិរន្តរ៍របស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ដោយហានិភ័យដែលត្រូវកែលម្អទាំងនោះរួមមានដូចខាងក្រោម៖

- ហានិភ័យឥណទានដែលធនាគារផ្តល់កម្ចីទៅដល់អតិថិជនគឺត្រូវធ្វើការពិនិត្យនិងសិក្សាលម្អិតបន្ថែមទៀតទៅលក្ខខណ្ឌបានកំណត់របស់ធនាគារជៀសវៀង ហានិភ័យក្នុងការសងត្រឡប់ប្រាក់ដើម និងការប្រាក់
- ហានិភ័យនៃការប្រមូលមកវិញនៃប្រាក់កម្ចី គឺមិនត្រូវចាក់ទុកថាមិនអាចប្រមូលឬ អាចទាត្រឡប់មិនបាននោះឡើយ។ គឺត្រូវកំណត់គោលការណ៍រួមទាំងធ្វើផែនការពេលវេលាជាក់លក្ខក្នុងការប្រមូលត្រឡប់មកវិញរាល់កម្ចីទាំងឡាយណាដែលគិតថាបាត់បង់ឬទទួលរងហានិភ័យនៃការសងត្រឡប់នៃកម្ចី។
- ហានិភ័យដែលអាចវាស់វែងបានគឺមុននឹងធ្វើការផ្តល់នូវរាល់កម្ចីគ្រប់ប្រភេទ គឺត្រូវសិក្សាឱ្យបានច្រើននិងស៊ីជម្រៅទៅលើទ្រព្យបញ្ចាំរបស់អតិថិជនដើម្បីអាចធនា ឱ្យបានថារាល់ទ្រព្យបញ្ចាំទាំងនោះអាចលក់ធ្វើការទូទាត់កម្ចីរបស់ពួកគេបានដោយមិនមានហានិភ័យក្នុងការបាត់បង់ណាមួយកើតមានប្រសិនបើពួកគេមិនអាចទូទាត់បំណុលទាន់ពេលវេលា ឬនៅថ្ងៃណាមួយដែលមិនបានដឹងមុន។

ដោយការផ្តល់ជាអនុសាសន៍ខាងលើរបស់ខ្ញុំបាទ គឺគ្រាន់តែជាផ្នែកមួយនៃការបានស្វែងយល់អំពីការសិក្សានៃរបាយការណ៍សវនកម្មហិរញ្ញវត្ថុរបស់សវករឯករាជ្យប៉ុណ្ណោះ។ គឺវាមិនមែនជាការវិនិច្ឆ័យទៅតាមការយល់ឃើញផ្ទាល់របស់ខ្ញុំបាទឡើយ។
ហើយសង្ឃឹមថាការចូលរួមជាយោបល់ទាំងនេះគឺ អាចជួយបានជាផ្នែកបន្ថែមទៀតក្នុងការធ្វើឱ្យប្រតិបត្តិការរបស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក តាន់តែរីកចម្រើនទៅមុខជានិរន្តរ៍ផងដែរ។

## ឯកសារយោង៖

១. របាយការណ៍សវនកម្មឯករាជ្យ របស់សវនករ ឆ្នាំ២០២៣
២. បណ្ណាល័យសិក្សាស្រាវជ្រាវ វិទ្យាស្ថាន វ៉ាន់ដា
៣. ឯកសារស្រាវជ្រាវ របស់និយ័តករគណនេយ្យនិងសវនកម្ម
៤. ដកស្រង់ចេញពី វេបសាយ Web: https://www.acar.gov.kh
៥. គេហទំព័ររបស់ធនាគារ អ៊ូរី Web: https://www.wooribank.com.kh

***កំណត់ចំណាំ៖** តំណភ្ជាប់របស់ធនាគារ អ៊ូរី (ខេមបូឌា) ម.ក ខាងលើលោក លោកស្រីអាចធ្វើទាញយកឯកសាររបាយការណ៍សវនកម្មឯករាជ្យទាំងមូលបានសម្រាប់ឆ្នាំដែលរងសវនកម្ម។

# ឧបសម្ព័ន្ធ

ដោយខ្ញុំបានធ្វើការសិក្សាទៅលើមុខវិជ្ជាសវនកម្ម លើរបាយការណ៍ហិរញ្ញវត្ថុ ការស្វែងរកព័ត៌មានដែលទាក់ទង់នឹងរបាយការណ៍នៃការស្រាវជ្រាវ ដូចនេះខ្ញុំនឹងធ្វើការភ្ជាប់ជាមួយនឹងរូបភាពជាតំណាងនៃកម្មវត្ថុ និងវត្តភាពនៃកិច្ចការស្រាវជ្រាវរបស់ខ្ញុំដូចខាងក្រោមៈ

## សៀវភៅពុម្ពវិទ្យាស្ថានវ៉ានដា សម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់







## របាយការណ៍សវនករ ឯករាជ្យសម្រាប់ឆ្នាំ ២០២៣


ធនាគារ វូរី (ខេមបូឌា) ម.ក

ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

លោក Hong Ju Kim

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី 26 ខែ មីនា ឆ្នាំ 2024


KPMG

តំណាងក្រុមហ៊ុន ខេភីអឹមជី ខេមបូឌា

Partner

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី26 ខែមីនា ឆ្នាំ2024

# របាយការណ៍សវនករ លើហានិភ័យ

**ធនាគារ អ៊ូរី (ខេមបូឌា) ម.ក**

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023

**32. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)**

**ខ. ហានិភ័យឥណទាន (ត)**

*(ឃ). គុណភាពឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនផុល (ត)*

*ការទទួលស្គាល់ការខាតបង់ឥណទានរំពឹងទុក*

ធនាគារអនុវត្តវិធីសាស្ត្រ 3 ដំណាក់កាល ដោយផ្អែកលើការផ្លាស់ប្តូរគុណភាពឥណទានចាប់តាំងពីបានការទទួលស្គាល់ដំបូង៖

| វិធីសាស្ត្រ3ដំណាក់កាល | ដំណាក់កាលទី1 | ដំណាក់កាលទី2 | ដំណាក់កាលទី3 |
|---|---|---|---|
| | ដំណើរការ | ក្រោមដំណើរការ | មិនដំណើរការ |
| ការទទួលស្គាល់ការខាតបង់ឥណទានរំពឹងទុក | រំពឹងថាឥណទាននឹងបាត់បង់រយៈពេល 12ខែ | រំពឹងថាឥណទាននឹងបាត់បង់ពេញអាយុកាល | រំពឹងថាឥណទាននឹងបាត់បង់ពេញអាយុកាល |
| លក្ខណៈវិនិច្ឆ័យ | មិនមានការកើនឡើងជាសារវន្តលើហានិភ័យឥណទានទេ | ហានិភ័យឥណទានដែលបានកើនឡើងជាសារវន្ត | ឥណទានដែលមានឱនភាពនៃតម្លៃលើទ្រព្យសកម្ម |
| មូលដ្ឋាននៃការគណនាចំណូលពីការប្រាក់ | តម្លៃយោងដុល | តម្លៃយោងដុល | តម្លៃយោងសុទ្ធ |

ធនាគារបានវាស់វែង ECL ដោយប្រើវិធីសាស្ត្រទូទៅ។ វិធីសាស្ត្រទូទៅមានការបែងចែកអតិថិជនជាបីដំណាក់កាលផ្សេងគ្នា យោងទៅតាមលក្ខណៈវិនិច្ឆ័យដំណាក់កាលដោយការវាយតម្លៃហានិភ័យឥណទាន។ ECL រយៈពេល 12ខែនឹងត្រូវបានគណនាសម្រាប់ដំណាក់កាលទី1 ខណៈពេលដែល ECL ពេញមួយជីវិតនឹងត្រូវបានគណនាសម្រាប់ដំណាក់កាលទី2 និងដំណាក់កាលទី3 ។ នៅកាលបរិច្ឆេទរបាយការណ៍នីមួយៗ ធនាគារនឹងវាយតម្លៃហានិភ័យឥណទាននៃគណនីនីមួយៗធៀបនឹងកម្រិតហានិភ័យនៅកាលបរិច្ឆេទដើម។

**ធនាគារ អ៊ូរី (ខេមបូឌា) ម.ក**

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023

**32. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)**

**ខ. ហានិភ័យឥណទាន (ត)**

*(ឃ). គុណភាពឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជនផុល (ត)*

*ការទទួលស្គាល់លើការរំពឹងទុកលើការខាតបង់ឥណទាន (ត)*

ឥណទានរយៈពេលវែង (ច្រើនជាងមួយឆ្នាំ)

| ដំណាក់កាល | ស្ថានភាពហានិភ័យឥណទាន | ចំណាត់ថ្នាក់ | ចំនួនថ្ងៃហួសកាលកំណត់ | សូចនាករណ៍នៃការយឺតយ៉ាវ |
|---|---|---|---|---|
| 1 | មិនមានការកើនឡើងជាសារវន្តលើហានិភ័យឥណទានទេ | ឥណទានធម្មតា | 0 ដល់ 29ថ្ងៃ | ដំណើរការ |
| 2 | ហានិភ័យឥណទានបានកើនឡើងជាសារវន្ត | ឥណទានឃ្លាំមើល | 30 ដល់ 89ថ្ងៃ | ក្រោមដំណើរការ |
| 3 | ឥណទានដែលមានឱនភាពនៃតម្លៃលើទ្រព្យសកម្ម | ឥណទានក្រោមស្តង់ដា | 90 ដល់ 179ថ្ងៃ | មិនដំណើរការ |
| | | ឥណទានជាប់សង្ស័យ | 180 ដល់ 359ថ្ងៃ | |
| | | ឥណទានខាតបង់ | ចាប់ពី 360ថ្ងៃ | |

ឥណទានរយៈពេលខ្លី (1ឆ្នាំ ឬតិចជាង)

| ដំណាក់កាល | ស្ថានភាពហានិភ័យឥណទាន | ចំណាត់ថ្នាក់ | ចំនួនថ្ងៃហួសកាលកំណត់ | សូចនាករណ៍នៃការយឺតយ៉ាវ |
|---|---|---|---|---|
| 1 | មិនមានការកើនឡើងជាសារវន្តលើហានិភ័យឥណទានទេ | ឥណទានធម្មតា | 0 ដល់ 14ថ្ងៃ | ដំណើរការ |
| 2 | ហានិភ័យឥណទានបានកើនឡើងជាសារវន្ត | ឥណទានឃ្លាំមើល | 15 ដល់ 30ថ្ងៃ | ក្រោមដំណើរការ |
| 3 | ឥណទានដែលមានឱនភាពនៃតម្លៃលើទ្រព្យសកម្ម | ឥណទានក្រោមស្តង់ដា | 31 ដល់ 60ថ្ងៃ | មិនដំណើរការ |
| | | ឥណទានជាប់សង្ស័យ | 61 ដល់ 90ថ្ងៃ | |
| | | ឥណទានខាតបង់ | ចាប់ពី 91ថ្ងៃ | |

ធនាគារនឹងប្រើប្រាស់ព័ត៌មានថ្ងៃផុតកំណត់ ("DPD") និងការចាត់ថ្នាក់របស់ NBC សម្រាប់លក្ខណៈវិនិច្ឆ័យដំណាក់កាល។

# គេហទំព័ររបស់ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក










**ធនាគារ អ៊ូរី (ខេមបូឌា) ម.ក**

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023**

**37. ការទិញអាជីវកម្មក្រោមការគ្រប់គ្រងរួម និងទុនបម្រុងរួមបញ្ចូលគ្នា (ត)**

ពល់ទ្រព្យសកម្ម និងបំណុលទាំងអស់របស់ WFC ត្រូវបានអនុវត្តតាមតម្លៃកត់ត្រាសុទ្ធដែលយោងតាមចុះបញ្ជីរបស់ធនាគារនៅថ្ងៃទី 1 ខែមករា ឆ្នាំ2020 ដែលជាកាលបរិច្ឆេទកំណត់នៃការរួមបញ្ចូលគ្នា។

ភាពលម្អៀងរវាងតម្លៃនៃភាគហ៊ុនដែលបានបោះផ្សាយដោយធនាគារ ជាមួយនឹងតម្លៃនៃទ្រព្យសកម្មសុទ្ធដែលបានទិញទាក់ទងនឹងការរួមបញ្ចូលគ្នានៃ WFC មានចំនួន 5,956,500 ដុល្លារអាមេរិក ត្រូវបានទទួលស្គាល់ថាជាទុនបម្រុងរួមបញ្ចូលគ្នាក្រោមវិធីសាស្ត្រការប្រាក់ប្តូរបញ្ចូលគ្នា (pooling-of-interest method)។

| | ដុល្លារអាមេរិក |
|---|---|
| ទ្រព្យសកម្មសុទ្ធនៅថ្ងៃដែលរួមបញ្ចូលគ្នា | 22,833,504 |
| ការបោះផ្សាយនៃដើមទុនជាមូលធនសម្រាប់រួមបញ្ចូលគ្នានាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 | (15,895,100) |
| ការផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020 | (981,904) |
| **ទុនបម្រុងពីការរួមបញ្ចូលគ្នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2020** | **5,956,500** |